ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត




- ព្រឹត្តិការណ៍កីឡា «ផ្ទើរជើងប្រវត្តិសាស្ត្រ» នៅលើភ្នំដងរែក
- រូបថតអតីតកាលដែលត្រូវចងចាំ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២២៩ ខែមករា ឆ្នាំ២០១៩

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ២២៩ ខែមករា ឆ្នាំ២០១៩

## មាតិកា

### សំបុត្រ


- អំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហម................................១
- ព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ»នៅលើភ្នំដងរែក........... ៤


### ផ្នែកឯកសារ


- រូបថតអតីតកាលដែលត្រូវចងចាំ..........................................៦


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- ខួបលើកទី៤០នៃថ្ងៃជ័យជម្នះ ៧មករា ................................ ៤២
- វិមាន ឈ្នះ ឈ្នះ ជានិមិត្តរូប ...........................................៤៤
- វិមានគោលនយោបាយឈ្នះ ឈ្នះ.........................................៤៦
- ព្រឹត្តិការណ៍កីឡា« ថ្មើរជើងប្រវត្តិសាស្ត្រ .............................៤៨


### វេទិកាពិភាក្សាសាធារណៈ


- ខួប២០ឆ្នាំនៃការចុះចូលរបស់ នួន ជា ................................ ៥១


### ទំព័រស្រាវជ្រាវរកគ្រួសារ


- បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម .............៥៤
- ហ៊ុយ ម៉ាន់ះ ពលទាហាន ..................................................៥៦
- អដ្ឋិធាតុគ្មានអ្វីជាអមតៈ ...................................................៥៨




សុន សេន នៅជំរំ១០០១ (ខេត្តព្រះវិហារអំឡុងដើមឆ្នាំ១៩៨០)


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ៣៧៥ ព.មប្រក

ចុះថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨


រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា


***ស្នេរលេខនេះ៖*** *ឆាំង យុ, លី សុខឃាង និង វ៉ាន់ ថាន់ពៅដារ៉ា,* ***អ្នកនិពន្ធ និងស្រាវជ្រាវ៖*** *ដារ៉ារដ្ឋ មេត្តា, ហូ ថុនា និង អ៊ុន សុដាវី* ***អ្នកបកប្រែ៖*** *សោម ប៊ុនថន* ***និពន្ធនាយកទូទៅ៖*** *សោម ប៊ុនថន* ***ជំនួយការនិពន្ធនាយក៖*** *ហូ ថុនា* ***ក្រាហ្វិកកុំព្យូទ័រ៖*** *គឹម សុវណ្ណដានី* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វើង* ***ក្រាហ្វិកកុំព្យូទ័រ៖*** *គឹម សុវណ្ណដានី* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វើង*



**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# អំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហមទៅលើព្រះវិហារកាតូលិក និងអ្នកកាន់សាសនាគ្រិស្តនៅក្នុងប្រទេសកម្ពុជា

សេចក្ដីសម្រេចនៅក្នុងសំណុំរឿង ០០២/០២ របស់សាលាក្ដីខ្មែរក្រហមបានផ្ដល់ឱកាស ដើម្បីគិតពិចារណាជាចម្បងទៅលើយុត្តិធម៌ ប៉ុន្តែយើងត្រូវតែទទួលស្គាល់ពីភាពខ្វះខាត និងដែនកំណត់របស់សាលាក្ដីនេះ ដោយមិនបានផ្ដល់ឱកាសដល់ជនរងគ្រោះជាច្រើនចែករំលែកបទពិសោធន៍របស់ខ្លួនៗ

អំពើប្រល័យពូជសាសន៍ គឺមិនងាយស្រួលកាត់ទោសនោះទេៗ ការដាក់ទោសទណ្ឌលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទាមទារឲ្យមានមូលដ្ឋានច្បាស់លាស់រួមមាន«ចេតនា»ក្នុងការសម្លាប់ ការផ្លាស់ទីកន្លែងប្រជាជនដោយផ្ដោតលើហេតុផលអត្តសញ្ញាណក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាជាដើមៗ សាលាក្ដីខ្មែរក្រហមដែលប្រជាជនទូទៅដឹងឮជាផ្លូវការថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មានយុត្តាធិការកាត់ទោសអំពើប្រល័យពូជសាសន៍លើប្រជាជនដោយផ្ដោតលើសាសនា ដូចឧក្រិដ្ឋកម្មដ៏ទៃទៀតដែរៗ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានយុត្តាធិការ ដោយព្យាយាមនាំយកជនសង្ស័យដែលបានធ្វើទុកបុកម្នេញលើសាសនាមកកាត់ទោស ដែលច្បាប់នេះស្ថិតនៅ



ព្រះវិហារគ្រិស្តសាសនានៅក្នុងក្រុងភ្នំពេញ (រូបថត ៖ វិគីភីឌា)



ព្រះវិហារគ្រិស្តសាសនានៅខេត្តបាត់ដំបង (រូបថត ៖ វិគីភីឌា)

ក្រោមក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ រួមទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិសម្រាប់ទង្វើទាំងឡាយណាដែលបានប្រព្រឹត្តក្នុងទ្រង់ទ្រាយធំធេង ឬជាប្រព័ន្ធ សំដៅប្រឆាំងទៅនឹងប្រជាជនដោយសារហេតុផលសាសនា។

សាលាក្តីខ្មែរក្រហម មានសិទ្ធិអំណាចនាំយកជនសង្ស័យមកកាត់ទោស ដោយសារការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ អនុលោមតាមអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៥៤ ដែលចែងអំពីការការពារសម្បត្តិវប្បធម៌នៅក្នុងជម្លោះប្រដាប់អាវុធ។ នៅខណៈពេលដែលកាលៈទេសៈជុំវិញឧក្រិដ្ឋកម្មទាំងនេះត្រូវបានពិភាក្សា នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាក់ទងទៅនឹងពុទ្ធសាសនិក និងអ៊ិស្លាមសាសនានោះ មិនមានការលើកឡើងអំពីឧក្រិដ្ឋកម្ម ឬសកម្មភាពទាំងឡាយដែលប្រឆាំងនឹងគ្រិស្តសាសនា ឬអ្នកមានជំនឿលើសាសនាគ្រិស្តឡើយ។

នៅចន្លោះពីខែមករា ឆ្នាំ១៩៧៥ ដល់ ខែមេសា ឆ្នាំ១៩៧៩ ខ្មែរក្រហមបានវាយកម្ទេចព្រះវិហារសាសនាគ្រិស្តសំខាន់ជាច្រើន និងបានសម្លាប់គ្រិស្តសាសនិកអស់ជាច្រើននាក់។ ព្រះវិហារកាតូលិកដំបូងនៅទីក្រុងភ្នំពេញ ដែលមានឈ្មោះថា ព្រះមាតា ត្រូវបានវាយបំផ្លាញ និងព្រះវិហារកាតូលិកនៅភ្នំពេញ ដែលអាចផ្ទុកមនុស្សបានរហូតដល់ ១០.០០០នាក់ ក៏ត្រូវបានដាក់គ្រាប់បែកបំផ្លាញដែរ។ មានរឿងរ៉ាវជាច្រើនពីសម័យនោះដែលបានរៀបរាប់ពីព្រះវិហារគ្រិស្តដែលត្រូវបានបំផ្លាញទាំងស្រុង ហើយមានបុព្វជិតជនជាតិខ្មែរជាច្រើនត្រូវបានសម្លាប់ រួមមាន ចូសេប ច្នារ សាលាស ដែលជាព្រឹទ្ធបូជាចារ្យកាតូលិកជនជាតិខ្មែរនៅកម្ពុជា។

សាលាក្តីខ្មែរក្រហម ត្រូវបានកម្រិតជាមួយអ្វីដែលសាលាក្តីនេះអាចធ្វើបានសម្រាប់ជនរងគ្រោះ។ តុលាការឧក្រិដ្ឋកម្ម ជាទូទៅមិនមានសំណងសម្រាប់ជនរងគ្រោះទេ ហើយសំណងណាមួយដែលសាលាក្តីផ្តល់ឲ្យជារឿយៗគឺជាសំណងនិមិត្តរូប។ ការចូលរួមចំណែកយ៉ាងសំខាន់បំផុតដែលតុលាការជាច្រើនបានផ្តល់ឲ្យគឺការបង្កើតឯកត្តកម្ម។

ឯកត្តកម្មរបស់តុលាការ ផ្តល់ឱកាសឲ្យជនរងគ្រោះនិយាយទៅកាន់ជនជាប់ចោទ ទៅកាន់សាធារណៈ និងក្មេងជំនាន់ក្រោយ ពីបទពិសោធន៍របស់គាត់ដែលបានឆ្លងកាត់របបខ្មែរក្រហម។ សូម្បីតែជនរងគ្រោះដែលមិនអាចនិយាយពីរឿងរ៉ាវរបស់ខ្លួនបាន កំណត់ត្រារបស់តុលាការមានសារសំខាន់ណាស់ ប្រសិនបើសម្រាប់តែគោលបំណងនៃការទទួលស្គាល់ការឈឺចាប់ជារួម។ ការទទួលស្គាល់រឿងរ៉ាវឈឺចាប់ជារួមនៅក្នុងតុលាការ ផ្តល់នូវការគោរពដល់ជនរងគ្រោះម្នាក់ៗ និងសមាជិកគ្រួសារជនរងគ្រោះដែលនៅរស់រានមានជីវិត ព្រមទាំងផ្តល់ឲ្យអ្នកប្រវត្តិសាស្ត្រជាមួយអំណះអំណាងកាន់តែច្រើនសម្រាប់កិច្ចការស្រាវជ្រាវរបស់ខ្លួន ដើម្បីព័ណ៌នានូវហេតុការណ៍ដែលបានកើតឡើង និងមូលហេតុដែលហេតុការណ៍នោះបានកើតឡើង។

ប៉ុន្តែវាតែងតែមានតុល្យភាពរវាងការបង្កើនទំហំកំណត់ត្រានៃអ្វីដែលបានកើតឡើង និងមូលហេតុដែលបានកើតឡើងជាមួយនឹងដែនកំណត់នៃប្រភពធនធានរបស់តុលាការ។ សំណួរគឺថាតើយើងគួរអនុញ្ញាតឲ្យការអភិរក្សធនធានរបស់តុលាការ (ឬហេតុផលផ្សេងទៀតណាដែលត្រូវបានផ្តល់ឲ្យ) ដើម្បីអនុញ្ញាតឲ្យមានការបង្ហាញមិនគ្រប់គ្រាន់ ឬការបង្ហាញខុសពីបទពិសោធន៍ពិតប្រាកដរបស់ក្រុមជនរងគ្រោះឬអត់។

ហាក់ដូចជាមានការយកចិត្តទុកដាក់តិចតួចបំផុត ដែលថាគ្រិស្តសាសនិកត្រូវខ្មែរក្រហមធ្វើទុក្ខបុកម្នេញ។ គ្មានអ្វីដែលគួរឲ្យសង្ស័យឡើយថា គ្រិស្តសាសនាដូចដែលបានបង្ហាញនៅក្នុងស្ថាបត្យកម្ម ពិធីបុណ្យ និងទំនៀមទម្លាប់ផ្សេងៗទៀតពីអតីតកាលភាគច្រើនបានបាត់បង់ និងបំផ្លាញក្នុងសម័យខ្មែរក្រហម។ សំណួរសំខាន់គឺថា តើគ្រិស្តបរិស័ទត្រូវបានកំណត់គោលដៅ ដោយផ្អែកលើហេតុផលសាសនាដូចគ្នានឹងពុទ្ធសាសនិក ឬអ៊ិស្លាមដែរឬទេ។ អង្គជំនុំជម្រះបានរកឃើញថា ក្រុមមួយចំនួនត្រូវបានខ្មែរក្រហមកំណត់គោលដៅដោយផ្អែកលើភាពខុសគ្នាខាងសាសនា។ អង្គជំនុំ

ជម្រះបានរកឃើញថា ជនជាតិចាមទទួលរងការគាបសង្កត់ចំពោះការអនុវត្តខាងសាសនារបស់ខ្លួន ហើយអ្នកទាំងនេះត្រូវបានធ្វើទុក្ខបុកម្នេញដោយសារជំនឿសាសនា។

អង្គជំនុំជម្រះក៏បានរកឃើញថា ពុទ្ធសាសនិកក៏ត្រូវទទួលរងការធ្វើទុក្ខបុកម្នេញដោយសារការប្រតិបត្តិសាសនាដែរ។ ខណៈពេលដែលអង្គជំនុំជម្រះបានរកឃើញថា ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅដោយផ្អែកលើពូជសាសន៍ និងជាតិពន្ធុ អង្គជំនុំជម្រះបែរជាមិនធ្វើការស៊ើបអង្កេត មិនពិភាក្សា ឬឆ្លើយសំណួរណាមួយដែលទាក់ទងនឹងការគោរពជំនឿគ្រិស្តសាសនារបស់ជនជាតិវៀតណាមទាំងនោះ ការធ្វើទុក្ខបុកម្នេញទៅលើអ្នកដែលមានជំនឿលើសាសនាគ្រិស្តឡើយ។

ប្រវត្តិសាស្ត្រនៃគ្រិស្តសាសនានៅក្នុងប្រទេសកម្ពុជាមានតាំងពីរាប់រយឆ្នាំមកហើយ។ ក្រុមអ្នកផ្សព្វផ្សាយសាសនាដំបូងបានមកដល់ប្រទេសកម្ពុជានៅសតវត្សរ៍ទី១៦ ហើយអ្នកទាំងនោះបានចូលរួម ឬគាំទ្រការងារផ្នែកសប្បុរសធម៌ ការងារល្អ វប្បធម៌ និងការសិក្សារៀនសូត្រ។ យើងអាចនិយាយបានថា ការខ្វះការយកចិត្តទុកដាក់ចំពោះការប្រព្រឹត្តមកលើក្រុមគ្រិស្តបរិស័ទគឺអាចផ្អែកទៅលើចំនួនតូចនៃក្រុមគ្រិស្តបរិស័ទដែលមាននៅក្នុងប្រទេសកម្ពុជានៅពេលនោះ។ មានការប៉ាន់ស្មានមួយបង្ហាញថា យ៉ាងហោចណាស់ នៅឆ្នាំ១៩៧០ មានក្រុមកាតូលិកជាង៦០.០០០នាក់ នៅក្នុងប្រទេសកម្ពុជា។

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨ ប្រទេសកម្ពុជានឹងប្រារព្ធពិធីជាប្រវត្តិសាស្ត្រ នៃការបញ្ចប់ចលនាខ្មែរក្រហមទាំងស្រុង។ នៅថ្ងៃនេះដែរ គឺមានរយៈពេល២០ឆ្នាំកន្លងទៅហើយ ដែល ខៀវ សំផន និង នួន ជា បានផ្តាច់ខ្លួនពីចលនាខ្មែរក្រហម។ នៅថ្ងៃនោះ ខៀវ សំផន បានជំរុញឲ្យប្រជាជនកម្ពុជាចាត់ទុក «រឿងរ៉ាវដែលកន្លងហួស ឲ្យវាហួសទៅចុះ» ទាក់ទងនឹងការស្លាប់របស់ប្រជាជនកម្ពុជាជាងពីរលាននាក់ ហើយ នួន ជា ក៏បាននិយាយដែរថា«សូមទុក(ការស្លាប់នេះ) ឲ្យទៅជាប្រវត្តិសាស្ត្រ។ នេះគឺជារឿងចាស់។ សូមទុកវាជារឿងអតីតកាល»។

អតីតកាលមិនដែលស្លាប់នោះទេ។ អតីតកាលនៅតែបន្តព្ទ នៅក្នុងអ្វីដែលយើងដឹង គិត និងធ្វើ។ យើងទាំងអស់គ្នាមានកាតព្វកិច្ចមិនភ្លេចអតីតកាល។ ការបំភ្លេចអតីតកាលគឺជាបទឧក្រិដ្ឋ។ យើងមិនអាចរំពឹងថាតុលាការនឹងទទួលខុសត្រូវទាំងស្រុងក្នុងការកត់ត្រាអតីតកាលនោះទេ។ យើងត្រូវតែបន្តពីចំណុចដែលសាលាក្តីខ្មែរក្រហមបានចាកចេញពីយើង បានបន្សល់ទុកឲ្យយើង ហើយខិតខំប្រឹងប្រែងដើម្បីធានាឲ្យបានថាប្រវត្តិសាស្ត្រ ដូចដែលបានឃើញតាមរយៈជនរងគ្រោះម្នាក់ៗត្រូវបានថែរក្សាទុកសម្រាប់មនុស្សជំនាន់ក្រោយ។

នៅត្រង់ចំណុចដែលកំណត់ត្រារបស់តុលាការមានកម្រិតមិនពេញលេញ ឬមិនគ្រប់គ្រាន់ យើងត្រូវតែផ្តួចផ្តើមដើម្បីការពារប្រវត្តិសាស្ត្រនេះ ដូច្នេះសំឡេងរបស់ជនរងគ្រោះទាំងអស់អាចត្រូវបានព្ទគ្រប់ពេលវេលា។

**ឆាំង យុ**

## ការចុះផ្សាយពីរឿងរ៉ាវប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូប ដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួននឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទលេខ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសព្ទលេខ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthbunthorn.s@dccam.org

Home Page: www.d.dccam.org

# ព្រឹត្តិការណ៍កីឡា «ថ្មើរជើងប្រវត្តិសាស្ត្រ» នៅលើភ្នំដងរែក ក្នុងស្រុកអន្លង់វែង

ព្រឹត្តិការណ៍កីឡា «ថ្មើរជើងប្រវត្តិសាស្ត្រ» នៅលើភ្នំដងរែក ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដើម្បីជាការចាប់ផ្តើមថ្មីសម្រាប់ស្រុកអន្លង់វែង និងដើម្បីគាំទ្រដល់សន្តិភាព សន្តិសុខ និងវិបុលភាព នៅក្នុងតំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម។

ព្រឹត្តិការណ៍កីឡានេះ នឹងប្រារព្ធធ្វើនៅវេលាម៉ោង ៦ ព្រឹក ថ្ងៃសៅរ៍ ទី៥ ខែមករា ឆ្នាំ២០១៩ ដែលចាប់ផ្តើមចេញដំណើរពីសារមន្ទីរប្រវត្តិសាស្ត្រអន្លង់វែង ឬសារមន្ទីរអតីតផ្ទះតាម៉ុក និងច្រកអន្តរជាតិជាំ។

ព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ» គឺជាព្រឹត្តិការណ៍សង្គមដំបូងបង្អស់ ដើម្បីប្រារព្ធខួបទី២០ឆ្នាំនៃការទទួលបានសន្តិភាពពេញលេញនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីការធ្វើសមាហរណកម្មចុងក្រោយនៅស្រុកអន្លង់វែង នៅក្នុងឆ្នាំ១៩៩៨។

អន្លង់វែង គឺជាស្រុកតូចមួយរបស់ខេត្តឧត្តរមានជ័យ ដែលស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ អន្លង់វែងមានព្រំដែនជាប់នឹងប្រទេសថៃ និងសម្បូណ៌ទៅដោយទីតាំងប្រវត្តិសាស្ត្រដ៏សោកសង្រេងជាច្រើនរបស់កម្ពុជា។ ខ្មែរក្រហមគឺជាឈ្មោះរបស់របបកុម្មុយនីស្តមួយ ដែលគ្រប់គ្រងប្រទេសកម្ពុជានៅក្នុងខែមេសា ឆ្នាំ១៩៧៥។ អស់រយៈពេលប្រហែល៤ឆ្នាំក្រោយមក ប្រជាជនកម្ពុជាបានទទួលរងនូវការធ្វើការដោយបង្ខំ គ្រោះទុរ្ភិក្ស អំពើទារុណកម្ម និងការសម្លាប់រង្គាល។ នៅក្រោមរបប ប៉ុល ពត របបនេះធ្វើឲ្យប្រជាជន បាត់បង់ជីវិត និងស្ទើរតែបានបំផ្លិចបំផ្លាញមូលដ្ឋានគ្រឹះរបស់សង្គមកម្ពុជាទាំងស្រុង ដោយរាប់ទាំងសាសនា និងវប្បធម៌។ គ្រួសារនីមួយៗត្រូវបែកខ្ញែកគ្នា មនុស្សជាទីស្រឡាញ់របស់ខ្លួនត្រូវបានបំបែក ហើយមនុស្សជាច្រើនត្រូវបានចាប់ខ្លួន និងសម្លាប់ចោល។ នៅពេលដែលរបបខ្មែរក្រហមបានដួលរលំនៅខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានគ្របដណ្តប់ទៅដោយរណ្តៅសាកសពរួមជាច្រើន។ បើទោះជារបបនេះ ត្រូវបានបណ្តេញចេញពីអំណាចនៅឆ្នាំ១៩៧៩ យ៉ាងណាក៏ដោយក៏សមាជិកខ្មែរក្រហមជាច្រើនបន្តធ្វើសង្គ្រាមទ័ពព្រៃ។ អស់រយៈពេលជិតពីរទសវត្សរ៍ ចលនាខ្មែរក្រហមបានគ្រប់គ្រងតំបន់មួយចំនួននៅក្នុងប្រទេសកម្ពុជា។ អន្លង់វែង ត្រូវបានស្គាល់ថាជាតំបន់តស៊ូចុងក្រោយរបស់ចលនាខ្មែរក្រហមនេះ។ អន្លង់វែងបានបន្សល់ទុកនូវស្លាកស្នាមនៃការគ្រប់គ្រងរបស់ខ្មែរក្រហម ហើយអតីតកម្មាភិបាលជាច្រើនបន្តរស់នៅក្នុងតំបន់នេះរហូតដល់សព្វថ្ងៃនេះ។

ព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ» ព្យាយាមតម្រង់ការចាប់អារម្មណ៍ទៅលើសារសំខាន់ផ្នែកប្រវត្តិសាស្ត្ររបស់អន្លង់វែង និងទៅលើចំណុចគោលនៃសន្តិភាព សន្តិសុខ និងវិបុលភាពរបស់ប្រទេសកម្ពុជា។ អន្លង់វែងគឺជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម ប៉ុន្តែតំបន់នេះក៏ជាចំណុចរបត់និមិត្តរូបមួយនៃការងើបចេញពីអតីតកាលដ៏សោកសង្រេងរបស់កម្ពុជាដែរ។ ការធ្វើសមាហរណកម្មរបស់អន្លង់វែងមានន័យស្មើនឹងការចាប់ផ្តើមសាជាថ្មីរបស់ប្រជាជនកម្ពុជានៅក្នុងតំបន់នេះ ដែលតស៊ូជម្នះទៅនឹងសង្គ្រាមនិងផលវិបាកទាំងឡាយ ដោយរាប់បញ្ចូលទាំងជំងឺ ពិការភាព ភាពក្រីក្រ និងការបាត់បង់ជីវិត។ ការធ្វើសមាហរណកម្មរបស់តំបន់នេះក៏មានន័យស្មើនឹងការចាប់ផ្តើមសាជាថ្មី សម្រាប់ប្រជាជ

នកម្ពុជាទាំងអស់គ្នាដែរ ដែលបានបញ្ចប់នូវរយៈកាលជាងបីទសវត្សរ៍នៃសង្គ្រាម អំពើប្រល័យពូជសាសន៍និងការសម្លាប់រង្គាល។

សព្វថ្ងៃនេះ អន្លង់វែងបន្តប់នូវភាពអាថ៌កំបាំង ដំណើរផ្សងព្រេង សម្បត្តិធម្មជាតិ និងហានិភ័យខ្លះដែរ។ តំបន់នេះធ្លាប់ជាចំណុចជួរមុខនៃជម្លោះព្រំដែនជាមួយប្រទេសថៃហើយ តំបន់ព្រៃស្រោងមួយចំនួននៅតែមិនអាចចូលទៅដល់ដោយសារតែគ្រាប់មីនជាដើម។ ប៉ុន្តែខណៈដែលសៀវភៅមគ្គុទ្ទេសក៍មុនៗ អាចពណ៌នាអន្លង់វែងថា ជាគោលដៅនៃដំណើរផ្សងព្រេងយ៉ាងប្រថុយប្រថាន តំបន់នេះបែរជាទទួលបាននូវសុខសុវត្ថិភាព និងសន្តិភាព ដែលមិននឹកស្មានដល់។ ព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ»នេះព្យាយាមគូសបញ្ជាក់ពីតម្លៃទាំងអម្បាលមាណនេះ តាមរយៈផ្លូវដើរប្រកបដោយទេសភាពដ៏ស្រស់បំព្រងដែលបាននាំអ្នកចូលរួមក្នុងព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ» និងសាធារណជនទាំងឡាយទៅកាន់ទីតាំងដ៏ស្រស់សោភាជាច្រើនរបស់ស្រុកអន្លង់វែង។

តំបន់នេះ ពោរពេញទៅដោយសម្បត្តិធម្មជាតិចម្រុះ និងសម្បូណ៌បែប ដែលអាចមើលឃើញក្នុងពេលនោះតែម្តង។ អ្នកចូលរួមក៏អាចមើលឃើញជ្រលងដងអូរតូចៗដូចម្រាមដៃ វាលស្រែស្រូវដ៏លន្វឹងលន្វោច ត្រពាំងបឹងបួរដែលមានទឹកថ្លាឈ្វេង និងទឹកជ្រោះដ៏អាថ៌កំបាំងក៏មាននៅទីនោះដែរ ហើយក៏អាចមើលឃើញប្រទេសថៃពីច្រាកភ្នំប្រកបដោយទេសភាពដ៏ស្រស់ស្អាត។ ព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ»ក៏មានផ្នែកខ្លះដែលស្ថិតនៅជាប់នឹងទីតាំង និងអគារប្រវត្តិសាស្ត្រ រួមមានទីបញ្ជាការ និងកន្លែងស្នាក់សំខាន់ៗរបស់មេដឹកនាំខ្មែរក្រហមទៀតផង។

ព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ»ក៏មានគោលបំណងផ្តល់ជូនសាធារណជននូវឱកាសក្នុងការធ្វើទស្សនកិច្ចនៃអតីតកាលរបស់ប្រទេសកម្ពុជា ព្រមទាំងឆ្លុះបញ្ចាំងអំពីអនាគតរបស់ប្រទេសកម្ពុជា។ តាមទស្សនៈជាច្រើន ប្រទេសកម្ពុជាបានក្លាយជាទីស្មសានចំពោះអំពើអាក្រក់ទាំងឡាយ ឬមនោគមន៍វិជ្ជា ភាពជាសត្រូវនិងយុទ្ធសាស្ត្រដែលបរាជ័យ។ ប៉ុន្តែ បើទោះជាជម្លោះនិងភាពត្រដាបត្រដួសនៅក្នុងប្រវត្តិសាស្ត្រក៏ដោយ ប្រទេសកម្ពុជាតំណាងឲ្យទឹកដីនៃសេចក្តីសង្ឃឹម និងឱកាស។ ព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ»នេះបាន និងកំពុងជំរុញទឹកចិត្តឲ្យមានព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ»សម្រាប់ជាការឆ្លុះបញ្ចាំង និងដើរឆ្ពោះទៅកាន់ផ្ទះរបស់ ប៉ុល ពត ដែលជាការស្តែងឲ្យឃើញជានិមិត្តរូបនៃសមត្ថភាពរបស់ប្រជាជនកម្ពុជាទាំងអស់ក្នុងការរៀនសូត្រ និងតស៊ូជម្នះទៅនឹងអតីតកាលរបស់ខ្លួន។ ខណៈដែលយើងមិនអាចគេចចេញពីប្រវត្តិសាស្ត្ររបស់យើង យើងក៏មិនត្រូវក្លាយជាទាសកររបស់ប្រវត្តិសាស្ត្រដែរ។ មានតែការរៀនសូត្រពីអតីតកាលតែប៉ុណ្ណោះទេ ទើបយើងអាចមានសេចក្តីសង្ឃឹមក្នុងការបោះជំហានទៅមុខតទៅទៀតបាន។

រៀបចំដោយៈ ក្រសួងទេសចរណ៍ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា រដ្ឋបាលសាលាខេត្តឧត្តរមានជ័យ សាលាស្រុកអន្លង់វែង និងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា

ការចុះឈ្មោះ សូមទំនាក់ទំនងៈ

លោក សុខ វណ្ណា ប្រធាននាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្តនិងកីឡាទេសចរណ៍ ទូរសព្ទ ០១១ ៨៣៣ ៣១៨

លោក ហោ ជិនវិរយុទ្ធ អភិបាល នៃគណៈអភិបាលស្រុកអន្លង់វែង ទូរសព្ទ ៖ ០៩៧ ៩៧៧ ៧៧៧៨

បណ្ឌិត ជុក ជំនោរ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍ ទូរសព្ទ ៖ ០៨១ ៨៨៨ ៨៧៧

លោកស្រី ធិនទី មុនីរស្មី ប្រធានមន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ ទូរសព្ទ ៖ ០១២ ៦៧៦ ៣៦៤

លោក លី សុខឃាង ប្រធានក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ទូរសព្ទ ៖ ០១២ ៩៧០ ៤៦៥

**លី សុខឃាង**

# រូបថតអតីតកាលដែលត្រូវចងចាំ

ទស្សនាវដ្តីស្វែងរកការពិត បានចុះផ្សាយលេខដំបូងរបស់ខ្លួនក្នុង ខែមករា ឆ្នាំ២០០០។ រាប់ចាប់តាំងពីឆ្នាំបោះពុម្ពផ្សាយលើកដំបូងមកដល់ពេលបច្ចុប្បន្ននេះ ទស្សនាវដ្តីស្វែងរកការពិតបានចេញផ្សាយចំនួន២២៩លេខ រួចមកហើយ ដើម្បីបំពេញតម្រូវការរបស់ប្រជាជនកម្ពុជាក្នុងការអានសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីរឿងរ៉ាវអតីតកាលក្នុងរបបខ្មែរក្រហម។ កន្លងមក ទស្សនាវដ្តីស្វែងរកការពិត បានបោះពុម្ពផ្សាយរូបថតពីអតីតកាលមួយចំនួនទាក់ទងនឹងរបបខ្មែរក្រហម ដែលរូបថតទាំងនេះបានឆ្លុះបញ្ចាំងទៅនឹងខ្លឹមសារអត្ថបទ និងព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។

ក្នុងខែមករា ឆ្នាំ២០១៩ នេះ ទស្សនាវដ្តីស្វែងរកការ-ពិត បានប្រមែប្រមូលឯកសាររូបថតដ៏កម្រពីរបបខ្មែរក្រហម ដែលរក្សាទុកនៅបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់បោះពុម្ពផ្សាយនៅលើទស្សនាវដ្តីស្វែងរកការពិត។ នៅក្នុងកម្រងរូបថតទាំងនោះរួមមាន៖ រូបថតរបស់អតីតកម្មាភិបាលជាន់ខ្ពស់ និងថ្នាក់ក្រោមខ្មែរក្រហម រូបថតប្រជា-ជន រូបថតរបស់ ប៉ុល ពត ជាមួយមេដឹកនាំកូរ៉េខាងជើង រូបថតគណៈប្រតិភូបរទេសដែលបានធ្វើដំណើរមកទស្សនកិច្ចប្រទេសកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែលមានកាលបរិច្ឆេទខុសៗគ្នា។ រូបថតទាំងអស់នេះបានក្រើនរំឭកដល់ប្រជាជនកម្ពុជាទូទៅថា របបខ្មែរក្រហមនឹងមិនត្រូវបានបំភ្លេចឡើយ។

កម្រងរូបថតទាំងអស់មិនត្រឹមតែបង្ហាញអំពីស្ថានភាពរស់នៅ របៀបរបបដឹកនាំ និងរចនាសម្ព័ន្ធដឹកនាំនៃរបបខ្មែរក្រហមតែប៉ុណ្ណោះទេ ប៉ុន្តែរូបថតទាំងនេះក៏បានបង្ហាញអំពីទំនាក់ទំនងនៃរបបកម្ពុជាប្រជាធិបតេយ្យជាមួយពិភពខាងក្រៅ រួមមានប្រទេសចិន គុយបា យូហ្គោស្លាវី កូរ៉េខាងជើង ម៉ាឡេស៊ី វៀតណាម ឡាវ និងប្រទេសភូមា ជាដើម។ មេដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហាក់បីដូចជាបានបង្ហាញភាពរីករាយ រាក់ទាក់ ស្វាគមន៍ និងមានមោទកភាពយ៉ាងខ្លាំងចំពោះការដឹកនាំរបស់ខ្លួនទៅកាន់មិត្តអន្តរជាតិ ប៉ុន្តែនៅខាងក្រោយរឿងរ៉ាវអាថ៌កំបាំងរបស់រូបថត ដែលយើងមិនអាចមើលឃើញ គឺជាទិដ្ឋភាពដ៏រន្ធត់ និងឃោរឃៅដែលក្រុមរបស់ខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនខ្លួន និងបានបណ្តាលឲ្យប្រជាជនស្លាប់អស់ជាងពីរលាននាក់ ដោយសារការបង្ខិតបង្ខំឲ្យធ្វើពលកម្មហួសកម្លាំង ការមិនផ្តល់អាហារឲ្យបរិភោគគ្រប់គ្រាន់ ការគ្មានថ្នាំសង្កូវសម្រាប់ព្យាបាល និងការយកទៅសម្លាប់។ ទោះបីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំតាំងពីដើម ខែមករា ឆ្នាំ១៩៧៩ ដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលគាំទ្រដោយវៀតណាមហើយ យ៉ាងណាក៏ដោយ ក៏ការបែកបាក់ការឈឺចាប់ខ្លោចផ្សាររបស់ប្រជាជនកម្ពុជានៅតែបន្តមានរហូតមកដល់សព្វថ្ងៃនេះ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ប្រជាជនកម្ពុជាប្រ-មាណជា៥លាននាក់ ដែលភាគច្រើនជាស្ត្រីមេម៉ាយ ក្មេងកំព្រា ជនពិការ គឺជាជនរងគ្រោះពីរបបដ៏ឃោរឃៅមួយនេះ។ ប្រជាជនទាំងនេះបានវិលត្រឡប់ទៅរកសាច់ញាតិស្រុកកំណើតរបស់ខ្លួន ខណៈដែលប្រជាជនខ្លះទៀតបាត់បង់សមាជិកគ្រួសារ និងសាច់ញាតិទាំងអស់។ ប្រជាជនទាំងនេះបានរស់នៅជាមួយភាពឈឺចាប់ និងមានកាតព្វកិច្ចស្តារប្រទេសជាតិដែលទទួលរងភាពខ្ទេចខ្ទាំឡើងវិញ។ យើងសង្ឃឹមថា ការបោះពុម្ពផ្សាយរូបថតទាំងនេះ នឹងអាចជួយធ្វើឲ្យប្រជាជនកម្ពុជារំឭកពីព្រឹត្តិការណ៍ និងបទពិសោធន៍របស់ខ្លួនដែលបានឆ្លងកាត់ពីរបបខ្មែរក្រហមឡើងវិញ និងចូលរួមការពារកុំឲ្យរបបខ្មែរក្រហមកើតឡើងម្តងទៀត។ រូបថតទាំងនេះគឺជារូបថតប្រវត្តិសាស្ត្រ ដែលគ្រប់គ្នាត្រូវយកចិត្តទុកដាក់ ថែរក្សា និងចងចាំ។

*ដារ៉ារដ្ឋ មេត្តា*



រូបខាងស្តាំទី១៖ អ្នកចម្រៀងឈ្មោះ សែម ក្រសួងឃោសនាការ

រូបខាងស្តាំទី៣៖ អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច

រូបខាងឆ្វេងទី១៖ សម

រូបខាងឆ្វេងទី២៖ ស៊ិន ហាវ អគ្គរដ្ឋទូតសាធារណរដ្ឋប្រ

រូបកណ្តាល៖ សុន សេន ឧប

រូបខាងស្តាំទី២៖ ឧត្តមសេនីយ៍ តឹង យុនសាន



រាប់ពីឆ្វេងទី១៖ ប៉ុល ពត ជានាយករដ្ឋមន្ត្រី និងជាលេខាបក្សកុម្មុយនីស្តកម្ពុជា

រាប់ពីឆ្វេងទី២៖ នួន ជា ប្រធានសភាតំណាងប្រជាជនកម្ពុជា និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា

រាប់ពីឆ្វេងទី៣៖ អៀង សារី ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស

រាប់ពីឆ្វេងទី៤៖ សុន សេន ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

រាប់ពីឆ្វេងទី៥(ឈរពីក្រោយ សុន សេន)៖ វ៉ន វេត ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

មិត្តលីន (ជនជាតិចិន) អ្នកបកប្រែចិន-ខ្មែរ
ជាមានិតចិន ប្រចាំកម្ពុជាប្រជាធិបតេយ្យ
នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ
រូបខាងស្តាំទី១៖ អ្នកបច្ចេកទេសចិន
ប្រធានក្រុមអ្នកជំនាញការចិនប្រចាំកម្ពុជា







បខាងមុខ៖ នួន ជា ប្រធានសភាតំណាងប្រជាជនកម្ពុជា និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា
រូបកណ្តាល៖ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ
រូបខាងក្រោយ៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស



រាប់ពីឆ្វេងទី១៖ នួន ជា ប្រធានសភាតំណាងប្រជាជនកម្ពុជា និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា
រាប់ពីឆ្វេងទី២៖ វ៉ន វេត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
រាប់ពីឆ្វេងទី៣៖ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ
រាប់ពីឆ្វេងទី៤៖ តា ម៉ុក លេខាភូមិភាគនិរតី
រាប់ពីឆ្វេងទី៥(អង្គុយពីក្រោយ តាម៉ុក)៖ ចេង អន ប្រធានគណៈកម្មាធិការឧស្សាហកម្ម
រាប់ពីស្តាំទី១៖ កែ ពក លេខាភូមិភាគឧត្តរ (ភូមិភាគកណ្តាល)
រាប់ពីស្តាំទី២៖ ដូ ជេត លេខាភូមិភាគបស្ចិម
រាប់ពីស្តាំទី៣៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស



DOCUMENTATION CENTER OF CAMBODIA





រូបខាងស្តាំទី១៖ នួន ជា

រូបខាងស្តាំទី១ ពាក់អាវពណ៌សៈ ឧត្តមសេនីយ៍ តឹង យុនសាន ប្រធានក្រុ
បតេយ្យ (ឧត្តមសេនីយ៍ តឹង យុន សានបានស្លាប់នៅកម្ពុជ
រូបខាងស្តាំទី២៖ នួន ជា ប្រធានសភាតំណាងប្រជាជនកម្ពុជ
រូបខាងស្តាំទី៣៖ អៀង សារី ឧបនា
រូបខាងស្តាំទី៤៖ សុន សេន ឧបនា



រូបខាងឆ្វេងទី២៖ នី យាន សមាជិកគណៈ
រូបខាងឆ្វេងទី៣៖ នួន ជា
រូបខាងស្តាំទី២៖ សេង ឆាយ



កមជំនាញការចិនប្រចាំនៅកម្ពុជាប្រជាធិ
ាដោយជម្ងឺគ្រុនចាញ់នៅចុងឆ្នាំ១៩៧(៥)
ា និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា
ាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស
យករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

តំបន់៣២



រូបខាងស្តាំទី១៖ នួន ជា
រូបខាងឆ្វេងទី១ ៖ហេង សិលា



*រូបខាងស្តាំទី១៖ អ្នកចម្រៀងឈ្មោះ សែម ក្រសួងឃោសនាការ*

*រូបខាងស្តាំទី៣៖ អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច*





រូបខាងឆ្វេងរូបទី៥ ពាក់វ៉ែនតា៖ សុន សេន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ
រូបខាងស្តាំទី៤ ចាប់ដៃជាមួយសុន សេន៖ ស៊ិន ជា អនុប្រធានគណៈកម្មការទាក់ទងអន្តរជាតិនៃគណៈមជ្ឈិមបក្សកុម្មុយនីស្តចិន
រូបខាងស្តាំទី៣៖ ពេជ ប៊ុនរ៉េត កម្មាភិបាលក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ
រូបខាងស្តាំទី២៖ នៃ សារ៉ាន់ ហៅយ៉ា លេខាភូមិភាគឦសាន



រូបខាងឆ្វេងទី២៖ ភ្ញៀវជនជាតិចិន, រូបខាងឆ្វេងទី៣៖ កុយ ធួន
រូបខាងស្តាំទី២៖ វន វ៉េត, រូបខាងស្តាំទី៣៖ ចេង អន, រូបខាងស្តាំទី៥៖ នួន ជា



រូបខាងឆ្វេងទី២៖ ភ្ញៀវជនជាតិចិន

រូបខាងឆ្វេងទី៣៖ កុយ ធួន

រូបខាងស្តាំទី២៖ វន វេត

រូបខាងស្តាំទី៣៖ ចេង អន

រូបខាងស្តាំទី៥៖ នួន ជា



រូបខាងឆ្វេងទី១៖ អ្នកបកប្រែជនជាតិឡាវ

រូបខាងស្តាំទី១៖ សុ ផានុវង្ស



រូបខាងស្តាំទី១៖ ហាក់សៀង ឡាយនី

រូបខាងឆ្វេងទី៣៖ គណៈប្រតិភូមកពីប្រទេសទីម័រខាងកើត

រូបខាងស្តាំទី១៖ សារិន ឆាក អតីតក្រសួងការបរទេស

រូបខាងស្តាំទី២៖ ង៉ោ ពីន(NGO PIN) អ្នកបកប្រែភាសាអង់គ្លេស របស់ក្រសួងការបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

រូបខាងស្តាំទី៣៖ សម សាន មន្ត្រីក្រសួងការបទេសកម្ពុជាប្រជាធិបតេយ្យ ជាអតីតឯកអគ្គរដ្ឋទូតប្រចាំកូរ៉េខាងជើង និងជាឯកអគ្គរដ្ឋទូតប្រចាំប្រទេសឡាវ ១៩៧៧






រូបខាងឆ្វេងទី១៖ សូ ហុង
រូបខាងស្តាំទី២៖ ដួន ប្រសិទ្ធ



រូបខាងស្តាំទី១៖ ឧត្តមសេនីយ៍ តឹង យុនសាន ប្រធានក្រុមជំនាញការចិន ប្រចាំនៅកម្ពុជាប្រជាធិបតេយ្យ

រូបខាងស្តាំទី៣៖ មិត្ត ស៊ៀ  អ្នកបកប្រែ ចិន-ខ្មែរ

រូបខាងស្តាំទី៤ចាប់ដៃ៖ សេន ឆៃ(SHEN CHIA) ប្រធានគណៈកម្មាធិការទាក់ទងអន្តរជាតិរបស់មជ្ឈិមបក្សកុម្មុយនីស្តចិន



*រូបខាងស្តាំទី១៖ ឧត្តមសេនីយ៍ តឹង យុនសាន ប្រធានក្រុមជំនាញការចិន ប្រចាំនៅកម្ពុជាប្រជាធិបតេយ្យ*

*រូបខាងឆ្វេងទី១៖ អ្នកបន្តពី ស៊ិន ជា*

*រូបកណ្តាល៖ មិន ឈិន (អ្នកខេត្តកំពង់ចាមទៅស្រុកចិន)*





រូបខាងឆ្វេងទី៣៖ សុខ ឆាន ឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំទីក្រុងហាណូយ



រូបកណ្តាលពាក់អាវពណ៌ស៖ ម្តាយរបស់ អៀង សារី ឈ្មោះ ត្រាន ធិឡិ





រូបខាងឆ្វេងទី១៖ សុខ
រូបខាងឆ្វេងទី២៖ ដេន
of the Sweden Kam
រូបខាងស្តាំទី១៖ អ្នកស្រី



រូបខាងឆ្វេងទី១៖ អៀង សារី
រូបខាងឆ្វេងទី៣៖ សុផា នុវង្ស សាធារណរដ្ឋប្រជាមានិតឡាវ
រូបខាងឆ្វេងទី៤៖ ខៀវ សំផន
រូបខាងស្តាំទី២៖ សូ ហុង អគ្គលេខាធិការក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ



ពាន អតីតឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំទីក្រុងហាណូយ

មាយដិន(Jan Myrdal ) សមាជិកគណៈប្រតិភូ មិត្តភាពស៊ុយអែតនិង កម្ពុជា( Member

puchea friendship Association delegate)

មាថា ហួរ (Martha Hour)



រូបខាងឆ្វេងទី៣៖ រដ្ឋមន្ត្រីក្រសួងសន្តិសុខប្រទេសគុយបា លោក Erco Gergio Voldez(ឆ្នាំ១៩៧៦ )



រូបខាងស្តាំជួរលើទី២៖ សុន សេន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ
រូបខាងស្តាំទី៥ ៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស
រូបខាងក្រោយបង្អស់៖ សួង ស៊ីគឿន កម្មាភិបាលនៅក្រសួងការបរទេស
រូបខាងស្តាំនៅពីលើខៀវ សំផន៖ ដួន ប្រសិទ្ធ កម្មាភិបាលនៅក្រសួងការបរទេស
រូបខាងស្តាំមុខគេទី១៖ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋ កម្ពុជាប្រជាធិបតេយ្យ
រូបកណ្តាលនៅខាងមុខគេ៖ នេ វិន ប្រមុខរដ្ឋប្រទេសភូមា



រាប់ពីស្តាំទី១៖ អង្គរក្សរបស់សម្តេច ព្រះនរោត្តសីហនុ








រូបទី១ខាងឆ្វេង៖ វ៉ាន់ វៀត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

រូបទី៣ខាងឆ្វេងលើកដៃចង្អុល៖ មី ប្រាង ប្រធានគណៈកម្មការគមនាគមន៍

រូបខាងឆ្វេងទី៨៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស

រូបខាងក្រោយអៀង សារី ពាក់អាវពណ៌ស៖ ឧត្តមសេនីយ៍ តឺង យុនសាន ប្រធានក្រុមជំនាញការចិនប្រចាំនៅកម្ពុជាប្រជាធិបតេយ្យ

រូបពាក់វ៉ែនតាឈរនៅពីក្រោយឧត្តមសេនីយ៍ តឺង យុនសាន៖ សមមិត្តស៊ូ (ជនជាតិចិន) អ្នកបកប្រែ



*រូបខាងឆ្វេងទី១៖ ជា សាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌*

*រូបខាងឆ្វេងទី២៖ មន្ត្រីក្រសួងការបរទេសសាធារណរដ្ឋប្រជាមានិតចិន*

*រូបខាងស្តាំទី១៖ បាន យាន*



គិម អ៊ីលស៊ុង (ប្រធានាធិបតេយ្យកូរ៉េខាងជើង) ទទួលជួបប៉ុល ពត និងអៀង សារី (ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៧)



*តាម៉ុក រូបកណ្តាល*


30

ថ្ងៃទី១៨ខែធ្នូ១៩៧៧

រូបខាងស្តាំទី២៖ ខៀវ សំផន

រូបខាងស្តាំទី៣៖ សម សាន ឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំសាធារណរដ្ឋប្រជាមានិតឡាវ

រូបខាងស្តាំទី៖ យុន យ៉ាត

រូបខាងឆ្វេងទី១៖ គណៈប្រតិភូជនជាតិឡាវ

រូបខាងឆ្វេងទី២៖ ចេង អន ប្រធានគណៈកម្មាធិការខស្សរាហកម្មនៃកម្ពុជាប្រជាធិបតេយ្យ

រូបខាងឆ្វេងទី៣៖ គណៈប្រតិភូឡាវ (Lao Delegate









ទស្សនកិច្ចរបស់គណៈប្រតិភូឡាវ នៅកម្ពុជាប្រជាធិបតេយ្យ
(១៨-២០ ខែធ្នូ ឆ្នាំ១៩៧៧)
រូបស្រ្តីខាងឆ្វេងទី១៖ យុន យ៉ាត រដ្ឋមន្ត្រីក្រសួងវប្បធម៌អប់រំ និងសិក្សាធិការ
រូបស្រ្តីខាងឆ្វេងទី២៖ អៀងធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច
រូបខាងស្តាំទី១៖ សុ ផានូវង្ស ប្រធានាធិបតីសាធារណរដ្ឋប្រជាមានិតឡាវ
រូបខាងស្តាំទី២៖ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ

# ខួបលើកទី៤០នៃថ្ងៃជ័យជម្នះ ៧ មករា គឺជាការរំឭកពីការបាត់បង់ និងការរស់រានមានជីវិតរបស់ប្រជាជនកម្ពុជាពីរបបខ្មែរក្រហម

*ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៩ គឺជាខួបលើកទី៤០ នៃការផ្តួលរំលំនៃរបបខ្មែរក្រហម។ ខួប៧មករា ត្រូវបានប្រារព្ធឡើងបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ហើយឆ្នាំនេះរាជរដ្ឋាភិបាលនឹងប្រារព្ធខួបទី៤០ ឆ្នាំនៅពហុកីឡាដ្ឋានជាតិអូឡាំពិក បន្ទាប់ពីការសម្ពោធវិមាននយោបាយឈ្នះ ឈ្នះ ដែលជានិមិត្តរូបនៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជានៅថ្ងៃ ទី២៩ ខែធ្នូ ឆ្នាំ២០១៨។ នៅក្នុងប្រទេសកម្ពុជា មានយុវជនប្រមាណជា៧០ភាគរយដែលបានកើតក្រោយរបបខ្មែរក្រហម។ យុវជនកម្ពុជានៅតែស្វែងយល់ពីរបបខ្មែរក្រហមតាមរយៈកម្មវិធីសិក្សាអំពីអំពើប្រល័យពូជសាសន៍ក្នុងប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជា ការចែករំលែករឿងរ៉ាវរបស់ឪពុកម្តាយដែលបានឆ្លងកាត់របបខ្មែរ-ក្រហមទៅកាន់សមាជិកក្នុងគ្រួសារ និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមួយចំនួនទៀត។*

*ការប្រារព្ធខួបនៃការផ្តួលរំលំរបបខ្មែរក្រហម ៧ មករា គឺជារំឭកដល់ការរំដោះប្រជាជនកម្ពុជាឲ្យរួចផុតពីការកាប់សម្លាប់យ៉ាងសាហាវព្រៃផ្សៃ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការនាំមកវិញនូវសិទ្ធិសេរីភាព និងវឌ្ឍនភាពសម្រាប់ពលរដ្ឋកម្ពុជារហូតមកដល់សព្វថ្ងៃ។*

*ប្រជាជនប្រមាណជា៥លាននាក់ ដែលបានរស់រានមានជីវិតក្រោយការដួលរលំរបបខ្មែរក្រហមបានរួមកម្លាំងជាមួយរាជរដ្ឋាភិបាល និងបានខិតខំកសាងប្រទេសឡើងវិញ។ ការប្រារព្ធខួបនៃការផ្តួលរំលំរបបខ្មែរក្រហមជារៀងរាល់ឆ្នាំ គឺជាការផ្តល់តម្លៃទៅដល់អាយុជីវិតប្រមាណជា២លានដែលបានស្លាប់ក្នុងរបបខ្មែរក្រហម និងការរួចរស់ជីវិតរបស់ប្រជាជនកម្ពុជាពីរបបដ៏ឃោរឃៅខ្មែរក្រហម ទោះបីជាមានទស្សនៈយល់ឃើញខុសគ្នា ពីវត្តមានរបស់កងទ័ពវៀតណាមក្នុងប្រទេសកម្ពុជារយៈពេលមួយទសវត្សរ៍យ៉ាងណាក៏ដោយ។*

នៅក្នុងឆ្នាំ១៩៧៨ កងទ័ពរណសិរ្សសាមគ្គី សង្គ្រោះជាតិកម្ពុជា ដោយមានជំនួយពីកងទ័ពស្ម័គ្រចិត្តវៀតណាម ដែលស្ថិតក្រោមមេបញ្ជាការវៀតណាមឈ្មោះ វ៉ាន់ ទៀនយុង បានដឹកនាំកងទ័ពស្ម័គចិត្តវៀតណាមប្រមាណ មួយសែន ពីរម៉ឺននាក់ចែកចេញជា១២កងពលធំ។ កងទ័ពស្ម័គ្រចិត្តវៀតណាម រួមមានកងទ័ពជើងទឹក ជើងអាកាស កងរថក្រោះ និងកងកាំភ្លើងធំ។ កងទ័ពរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាមានចំនួន៩កងវរសេនាតូច ត្រូវបានបង្កើតឡើងនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ក្នុងស្រុកស្នួល ខេត្តក្រចេះ បានធ្វើការសហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាម។ កងទ័ពទាំងពីរបានធ្វើប្រតិបត្តិការនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨។ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយលុកទៅលើរបបកម្ពុជាប្រជាធិបតេយ្យនៅ៣ទីតាំងផ្សេងៗគ្នាក្នុងនោះរួមមាន កងទ័ព៣កងវរសេនាតូចបានវាយលុកចូលខេត្តស្វាយរៀង តាមបណ្តោយផ្លូវជាតិលេខ១ កងទ័ព៣វរសេនាតូចទៀតបានវាយចូលខេត្តកំពង់ចាមនិងកងទ័ព៣កងវរសេនាតូចចុងក្រោយបានធ្វើការវាយលុកចូលស្រុកស្នួលខេត្តក្រចេះ។ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម បានវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ និងខេត្តកណ្តាល បានដោយជោគជ័យនៅថ្ងៃទី៧ខែមករា ឆ្នាំ១៩៧៩ ដោយប្រើរយៈពេល២១ថ្ងៃ។

ទោះបីយ៉ាងណា កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិ

កម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមបានធ្វើការវាយលុក និងកាន់កាប់បានខេត្តក្រចេះ តាំងពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨ មកម្ល៉េះ និងបានវាយរំដោះតំបន់ផ្សេងៗទៀតជាបន្តបន្ទាប់ៗ ចំណែកតំបន់ជាប់សមុទ្រ ដូចជា ខេត្តកោះកុង និង កំពង់សោម ត្រូវបានរំដោះ និងកាន់កាប់ក្រោយបង្អស់គឺនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៩។

ការរំដោះបានទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ ១៩៧៩ ដែលជាតំបន់រដ្ឋបាលនៃប្រទេសកម្ពុជា គឺជាជោគជ័យដ៏ធំធេងរបស់កងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម។

តាមរយៈសេចក្តីថ្លែងការណ៍របស់លោកប្រធាន ហេង សំរិន នៅក្នុងខួបលើកទី១ នៅថ្ងៃ ជ័យជម្នះ ៧ មករា ឆ្នាំ១៩៨០ បានរៀបរាប់ពីការស្តាប្រទេសជាតិឡើងវិញក្នុងនោះ រួមមាន ៖ វិស័យសុខាភិបាល គ្រូពេទ្យដែលរស់រានមានជីវិតក្រោយឆ្នាំ១៩៧៩ដែលមានតែ៤៨នាក់តែប៉ុណ្ណោះនៅទូទាំងប្រទេស ខណៈពេលមានប្រជាជនប្រមាណជា២លាននាក់បានទៅពិនិត្យជំងឺ និងត្រូវការព្យាបាលជាបន្ទាន់ៗ វិស័យឧស្សាហកម្មរបស់កម្ពុជានៅទីក្រុងភ្នំពេញចាប់ផ្តើមដំណើរការឡើងវិញ។ នៅឆ្នាំ១៩៨០ មានរោងចក្រ សហគ្រាសប្រមាណជា៤០ បានធ្វើសកម្មភាពរបស់ខ្លួន និងផលិតឡើងវិញ។ ចំណែកវិស័យកសិកម្មបានដាំដុះឡើងវិញ ទោះបីគ្មានឧបករណ៍កសិកម្មប្រើប្រាស់គ្រប់គ្រាន់ៗ មធ្យោបាយដឹកជញ្ជូននៅក្នុងឆ្នាំ១៩៨០ រថភ្លើងបានដំណើរសារជាថ្មី ពីភ្នំពេញទៅកំពង់សោម។ ចំណែកផ្លូវទឹកមានកំពង់ផែខេត្តព្រះសីហនុ សម្រាប់ធ្វើការផ្លាស់ប្តូរទំនិញទៅកាន់ទីផ្សារក្នុងពិភពលោក ហើយអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបានដំណើរការម្តងទៀត ក្នុងពេលដំណាលគ្នាផងដែរ។

របបសាធារណរដ្ឋប្រជាមានិតកម្ពុជា មានទំនាក់ទំនងជាមួយប្រទេសសង្គមនិយម វៀតណាម និងសហភាពសូវៀត ព្រមទាំងធ្វើការពង្រីកទំនាក់ទំនងជាមួយប្រទេសចំនួន២៩ ផ្សេងទៀត ដែលមានស្ថានទូតប្រចាំនៅក្នុងប្រទេសកម្ពុជា។ សាលារៀនបានបើកទទួលសិស្ស និស្សិត ប្រមាណជាង ៧ សែននាក់ឲ្យចូលរៀន។ រដ្ឋាភិបាលបានប្រមូល និងបង្កើតជាក្រុមប្រវាស់ដៃ ឬក្រុមសាមគ្គីបង្កបង្កើនផល ដាំដុះស្រូវ និងដំណាំផ្សេងៗ ព្រោះរដ្ឋាភិបាលខ្វះខាតកម្លាំងពលកម្ម។ ក្នុងនោះមានការចាត់តាំងក្រុមបង្កបង្កើតផលដែលមានកម្លាំងប្រមាណជា៤៥.០០០ពាន់ក្រុម (ក្នុងមួយក្រុមមានសមាជិកពី១០ទៅ១៥គ្រួសារ)។

ដើម្បីជាការចងចាំចំពោះគុណបំណាច់នៃកងទ័ព ដែលបានពលីអាយុជីវិតរបស់ខ្លួនក្នុងបុព្វហេតុជាតិ និងអបអរសាទរដល់ថ្ងៃដែលប្រជាជនកម្ពុជាមានសេរីភាព ឯករាជ្យ ជួបជុំគ្រួសារ និង ការកសាងជីវិតឡើងវិញ រដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី៧ ខែមករា ជាថ្ងៃរំឭកខួបនៃការទទួលបានជ័យជម្នះលើរបបខ្មែរក្រហម។ គ្រប់ស្ថាប័នរដ្ឋ និងឯកជននានា បានឈប់សម្រាករយៈពេលមួយថ្ងៃជារៀងរាល់ឆ្នាំ។ ក្នុងឱកាសក្នុងការប្រារព្ធចងចាំស្មារតី ៧ មករា នេះដែរ នៅតាមស្ថាប័នរដ្ឋមួយចំនួនដូចជា សាលាខេត្ត សាលាស្រុក ឬឃុំទូទាំងប្រទេសនៃព្រះរាជាណាចក្រកម្ពុជាបានប្រារព្ធពិធីថ្ងៃ ៧ មករា យ៉ាងឱឡារិក ដោយមានការចូលរួមពីថ្នាក់ដឹកនាំរបស់ស្ថាប័នរដ្ឋ ព្រះសង្ឃ សាធារណៈជនទូទៅ សិស្សានុសិស្ស ក្រុមកាយរិទ្ធ និងកាកបាទក្រហម។

នៅថ្ងៃទី៧ ខែមករា ជាថ្ងៃប្រវត្តិសាស្ត្រដែលរំឭកពីការបាត់បង់ និងការរស់រានមានជីវិតរបស់ប្រជាជនកម្ពុជាពីរបបខ្មែរក្រហម។ ថ្ងៃនេះក៏ជាថ្ងៃដែលរដ្ឋាភិបាល និងជនរងគ្រោះកម្ពុជាបានខិតខំប្រឹងប្រែងកសាងប្រទេសឡើងវិញ ក្រោយពីការបំផ្លិចបំផ្លាញស្ទើរទាំងស្រុងពីរបបខ្មែរក្រហម។

**ដារ៉ារដ្ឋ មេត្តា**

# វិមានឈ្នះ ឈ្នះ ជានិមិត្តរូបនៃការបញ្ចប់សង្គ្រាមដ៏យូរអង្វែង នៅក្នុងប្រទេសកម្ពុជាគួរត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាប្រទេសអាស៊ាន

របបខ្មែរក្រហមបានឡើងគ្រប់គ្រងប្រទេសកម្ពុជារយៈពេលប្រមាណតែជាងបីឆ្នាំតែប៉ុណ្ណោះ ប៉ុន្តែរបបនេះបានបន្សល់នូវសង្គ្រាម ភាពវឹកវរ អំពើហិង្សា គំនុំ និងភាពបែកបាក់សង្គមយ៉ាងធ្ងន់ធ្ងរឲ្យប្រជាជនកម្ពុជា និងមេដឹកនាំជំនាន់ក្រោយដោះស្រាយប្រមាណ ជាងពាទសវត្សរ៍ៗ ទោះបីរបបខ្មែរក្រហមបានដួលរលំទៅនៅដើមឆ្នាំ១៩៧៩ ហើយក៏ដោយក៏របបនេះ បានប្រមូលកម្លាំងរបស់ខ្លួនឡើងវិញ នៅតាមបណ្តោយព្រំដែនជាប់នឹងប្រទេសថៃ និងបានកាន់កាប់តំបន់រដ្ឋបាលនៅតាមបណ្តាខេត្តមួយចំនួនទៀតផងៗ មិនត្រឹមតែប៉ុណ្ណោះ របបខ្មែរក្រហមក៏នៅតែមានការទទួលស្គាល់ និងគាំទ្រពីភាពស្របច្បាប់ពីប្រទេសលោកខាងលិចមួយចំនួន និងជាពិសេសក្នុងចំណោមប្រទេសអាស៊ានខ្លះ ដោយបានធ្វើមិនដឹងមិនឮ ឬមើលរំលងពីភាពសាហាវឃោរឃៅដែលក្រុមមេដឹកនាំខ្មែរបានប្រព្រឹត្តមកលើប្រជាជនកម្ពុជាៗ ខ្មែរក្រហមបានធ្វើឲ្យប្រជាជនកម្ពុជាស្លូតត្រង់ប្រមាណជាងពីរលាននាក់បាត់បង់ជីវិត ហើយហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជា



វិមានឈ្នះ ឈ្នះ មើលពីផ្នែកខាងលិច

ស្ទើរតែបាត់បង់ទាំងស្រុង។

ការបាត់បង់ដ៏ធំនេះគឺជាកាតព្វកិច្ចដ៏ធ្ងន់ធ្ងរដែលប្រជាជនកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា (ក្រោយមកប្តូរមកជា រដ្ឋកម្ពុជា) ដែលត្រូវបានបដិសេធ និងមិនមានអាសនៈនៅក្នុងអង្គការសហប្រជាជាតិ ត្រូវស្តា និងបង្រួបបង្រួមប្រទេសជាតិដែលបែកបាក់ឡើងវិញ។ ដូច្នេះ ការដែលនាំមេដឹកនាំខ្មែរក្រហម និងកម្លាំងខ្មែរក្រហមដែលនៅមានការគាំទ្រពីប្រទេសមួយចំនួន និងនៅមានអាវុធនៅដៃនៅឡើយ គឺជាកិច្ចការដ៏លំបាកមួយ និងស្មុគ្រស្មាញ។ ទោះបីយ៉ាងណាក៏ដោយ គំនិតផ្តួចផ្តើមមួយត្រូវបានអនុវត្តឡើង ដើម្បីនាំក្រុមខ្មែរក្រហមមកចូលរួមជាមួយប្រទេសជាតិវិញ គឺ ១) ការធានានូវអាយុជីវិត និងរូបរាងកាយ ២) ធានាចំពោះអាជីព និងមុខរបរ និង៣) ធានាចំពោះកម្មសិទ្ធិចលនទ្រព្យ និងអចលនទ្រព្យ។ គំនិតផ្តួចផ្តើមនេះបានក្លាយ



ទៅជាយុទ្ធសាស្ត្រមួយរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើឲ្យមានការជឿទុកចិត្តពីក្រុមខ្មែរក្រហម ហើយជាបន្តបន្ទាប់មេដឹកនាំខ្មែរក្រហម និងយោធាខ្មែរក្រហម នៅតំបន់ភ្នំវល្លិ៍ ម៉ាឡៃ ប៉ៃលិន សំឡូត បានធ្វើសមាហរណកម្ម និងចុះចូល។ នួន ជា និង ខៀវ សំផន រួមទាំងមេដឹកនាំយោធានៅតំបន់អន្លង់វែង ដែលជាតំបន់រឹងមាំចុងក្រោយរបស់ខ្មែរក្រហម បានចុះចូលជាមួយរាជរដ្ឋាភិបាលដែលដឹកនាំដោយ សម្តេច ហ៊ុន សែន នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨។ ការចុះចូលនេះ គឺជាការបញ្ចប់សង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជាដែលមានរយៈពេលប្រមាណពីរទសវត្សរ៍។

ទោះបីយ៉ាងណា ការចរចាបង្រួមបង្រួម និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីបញ្ចប់របបខ្មែរក្រហម មិនត្រូវបានគេយល់ឃើញពីសារសំខាន់របស់វានៅក្នុងតំបន់ និងពិភពលោកឡើយ។ ដូច្នេះខ្ញុំគិតថា ការដាក់បញ្ចូលគោលនយោបាយ ឈ្នះ ឈ្នះ នៅក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំជាប្រយោជន៍ដ៏សំខាន់ ដែលធ្វើឲ្យក្មេងៗយល់ពីតម្លៃនៃសន្តិភាព និងការផ្សះផ្សាជាតិ និងលើកទឹកចិត្តប្រជាជនកម្ពុជាឲ្យរួបរួមគ្នាដើម្បីអនាគតដ៏ត្រចះត្រចង់។ នយោបាយ ឈ្នះ ឈ្នះ នេះ ក៏គួរត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ាន ស្តីអំពីសិទ្ធិមនុស្ស សហគមន៍ និងពិភពលោកដែរ ព្រោះនយោបាយ ឈ្នះ ឈ្នះ ជាយុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជាដែលធ្វើឲ្យមានការយល់ដឹង និងរួមចំណែកជាមួយមេរៀនប្រវត្តិសាស្ត្រស្តីពីអំពើប្រល័យពូជសាសន៍ សន្តិភាព និងការដោះស្រាយជម្លោះនៅក្នុងតំបន់ និងពិភពលោក។

វិមាន ឈ្នះ ឈ្នះ ត្រូវបានសម្ពោធនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០១៨ក្រោមអធិបតីភាពសម្តេចហ៊ុនសែនដែលមានរយៈពេល ២០ឆ្នាំ បន្ទាប់ពីការចុះចូលរបស់មេដឹកនាំខ្មែរក្រហមនិងកម្លាំងខ្មែរក្រហមទាំងអស់ជាមួយរាជរដ្ឋាភិបាលកម្ពុជា។ វិមាននេះតំណាងឲ្យសន្តិភាព និងការបង្រួបបង្រួមជាតិ ដែលប្រជាជនកម្ពុជាត្រូវសិក្សា និងយល់ដឹង។ **សោម ប៊ុនថន**

# វិមានគោលនយោបាយឈ្នះឈ្នះ គឺជានិមិត្តរូបនៃសុខសន្តិភាព និងការបញ្ចប់សង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជា

នៅព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨ វិមានគោលនយោបាយ ឈ្នះឈ្នះ ដែលមានទីតាំងស្ថិតនៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ត្រូវបានរៀបចំការសម្ពោធជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ដោយមានការអញ្ជើញចូលរួមពីប្រជាជន សិស្សានុសិស្ស មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ឥស្សរជនជាតិ និងអន្តរជាតិសំខាន់ៗមកពីប្រទេសចិន វៀតណាម ឡាវ និងប្រទេសថៃ។

វិមានគោលនយោបាយ ឈ្នះឈ្នះ បានចាប់ផ្ដើមសាងសង់ឡើងនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ លើផ្ទៃដីទំហំដីជាង ៨ហិចតា និងបានចំណាយទឹកប្រាក់អស់ប្រមាណជាង ១០ លានដុល្លារ ដែលចំនួនទឹកប្រាក់នេះនឹងកើនឡើងបន្ថែមទៀតសម្រាប់ចំណាយទៅលើការសាងសង់សំណង់ដែលសេសសល់ និងមិនទាន់បញ្ចប់រួចរាល់។ ការសាងសង់វិមាននេះឡើង គឺដើម្បីរំឭកដល់គុណូបការៈរបស់បុព្វបុរសខ្មែរគ្រប់សម័យកាល ដែលបានលះបង់អាយុជីវិតក្នុងបុព្វហេតុជាតិមាតុភូមិ។ វិមាននេះក៏ជានិម្មិតរូបនៃសុខសន្តិភាពដែលកម្ពុជាទទួលបានក្រោយពីបញ្ចប់សង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃជាច្រើនទសវត្សរ៍កន្លងមក។ ក្នុងន័យនៃពាក្យ «គោលនយោបាយ ឈ្នះឈ្នះ» គឺជាស្នូល និងជាឧបករណ៍ដ៏សំខាន់បំផុតនៃទស្សនវិជ្ជាសន្តិភាពរបស់កម្ពុជា ហើយវាគឺជាមេរៀនដ៏សំខាន់បំផុតផងដែរ ដែលបានដកស្រង់ចេញពីការសាកល្បង និងការតស៊ូយ៉ាងប្ដូរផ្ដាច់អស់រយៈពេលជាច្រើនទសវត្សរ៍ៗ ពាក្យគន្លឹះនៃ «គោលនយោបាយ ឈ្នះឈ្នះ» គឺជាការទទួលស្គាល់ថា នៅក្នុងការធ្វើសង្គ្រាមបំផ្លិចបំផ្លាញប្រាកដជាមិនអាចមានអ្នកឈ្នះនោះទេ ហើយការចងអាឃាតព្យាបាទ ក៏មិនអាចនាំមក


ប្រជាពលរដ្ឋ សិស្ស និស្សិត មន្ត្រីរាជការ និងទាហានចូលរួមសម្ពោធ វិមាន ឈ្នះ ឈ្នះ

នូវសន្តិភាពជូនប្រទេសជាតិ និងប្រជាជនបានដែរ។ នៅក្នុងសុន្ទរកថា សម្តេច ហ៊ុន សែន បានសង្កត់ធ្ងន់ទៅលើការបញ្ចប់សង្គ្រាមស៊ីវិល និងការប្រទូស្តរ៉ាយជាមួយខ្មែរក្រហម ដោយសម្តេចបានសម្រេចប្រើប្រាស់នូវគោលការណ៍សំខាន់បីយ៉ាងគឺ៖

ទី១) ការធានានូវសុវត្ថិភាពខាងផ្នែកសន្តិសុខផ្ទាល់ខ្លួនរបស់បុគ្គល និងគ្រួសារដែលស្ម័គ្រចិត្តបញ្ចប់សង្គ្រាម និងការប្រយុទ្ធ ហើយវិលត្រឡប់មករួមរស់នៅក្នុងចរន្តគោលនៃសង្គមជាតិវិញ។

ទី២) ការធានានូវសុវត្ថិភាពខាងផ្នែកអាជីព ដែលផ្តល់ជូននូវអ្នកទាំងនោះ នូវលទ្ធភាពគ្រប់គ្រាន់ក្នុងការបន្តមុខរបរ និងការរកស៊ីចញ្ចឹមជីវិតដែលគេធ្លាប់មានកន្លងមក។

ទី៣) ការធានានូវសុវត្ថិភាពខាងផ្នែកកម្មសិទ្ធិដែលគេធ្លាប់មាន និងកាន់កាប់ក្នុងរយៈពេលកន្លងមក ដោយគ្មានការដកហូត ឬរុះរើ។

គោលនយោបាយទាំងបីយ៉ាងនេះ គឺជាវិធីសាស្ត្រសក្តិសិទ្ធិ និងមានប្រសិទ្ធភាពបំផុតសម្រាប់ព្យាបាលមុខរបួស និងការប្រេះឆាដែលបន្កឡើងដោយសង្គ្រាមស៊ីវិល និងជម្លោះផ្ទៃក្នុងជាតិ ក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងមកនេះ ហើយបង្កើតឡើងនូវ«កាលានុវត្តភាព» សម្រាប់ការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកម្ពុជា។ វិមានគោលនយោបាយ ឈ្នះឈ្នះ នេះនឹងក្លាយជាកេរមរតកសម្រាប់កូនចៅខ្មែរជំនាន់ក្រោយដែលបន្តប់ទៅដោយអត្តន័យស្ថាបត្យកម្ម និងជាបណ្ណាល័យសម្រាប់សិក្សាស្រាវជ្រាវ។

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨ នេះដែរ ក៏ជាខួបលើទី២០ឆ្នាំ ដែល ខៀវ សំផន, នួន ជា និង អៀង សារី បានឡើងមកជួបសម្តេចនៅភូមិគ្រឹះនៅក្រុងតាខ្មៅ ដែលជាថ្ងៃលែងមានកម្លាំងខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជាតទៅទៀត ហើយសង្គ្រាមស៊ីវិលក៏ត្រូវបានបញ្ចប់ដែរ។

ខាងក្រោមនេះ គឺជាទស្សនៈយល់ឃើញជុំវិញរឿងរ៉ាវនៃការសាងសង់វិមានគោលនយោបាយ ឈ្នះឈ្នះ ពីសាធារណជនដែលបានចូលរួមក្នុងកម្មពិធីសម្ពោធវិមានគោលនយោបាយ ឈ្នះឈ្នះ ដូចតទៅ៖

ឃ្លាំង គឹម អាយុ៧៥ឆ្នាំ គឺជាអតីតកងទ័ពរណសិរ្សសាមគ្គីរួបរួមជាតិកម្ពុជា បានរៀបរាប់ថា «សម្រាប់ខ្ញុំពិតជាមានមោទកភាពចំពោះស្នាដៃនៃការសាងសង់វិមានគោលនយោបាយ ឈ្នះឈ្នះ នេះឡើង ព្រោះស្តូបវិមាននេះ បានឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលធ្លាប់បានឆ្លងកាត់សង្គ្រាមជាច្រើនទសវត្សរ៍កន្លងមក។ ប្រទេសកម្ពុជាបានឆ្លងកាត់នូវរបបជាច្រើន ហើយរបបនីមួយៗបានបំផ្លិចបំផ្លាញដោយសង្គ្រាម និងបណ្តាលឲ្យប្រជាជនកម្ពុជាស្លូតត្រង់ស្លាប់ប្រមាណជាងពីរលាននាក់។ ខ្ញុំសង្ឃឹមថា ស្តូបវិមានគោលនយោបាយ ឈ្នះឈ្នះ នេះនឹងជួយរំឭកពីប្រវត្តិសាស្ត្រដែលធ្លាប់បានកើតឡើង ដើម្បីជៀសវាងកុំឲ្យកូនចៅខ្មែរជំនាន់ក្រោយភ្លេចនូវប្រវត្តិសាស្ត្ររបស់ជាតិខ្លួន»។

ឆេង លុន អាយុ៦២ឆ្នាំ បានបញ្ចេញនូវមតិផ្ទាល់ខ្លួនថា «ចំពោះរូបខ្ញុំ ដែលធ្លាប់បានឆ្លងកាត់អស់ជាច្រើនសម័យកាលកន្លងមក ហើយខ្ញុំក៏មានរឿងរ៉ាវជាច្រើនដែលបានបន្សល់ទុក និងមិនអាចបំភ្លេចបានរហូតមកដល់សព្វថ្ងៃនេះ។ ជាពិសេស គឺរបបខ្មែរក្រហមដែលធ្វើឲ្យសមាជិកគ្រួសាររបស់ខ្ញុំបាត់បង់អាយុជីវិតស្ទើរតែទាំងអស់ នៅក្នុងអំឡុងពេលដែលខ្មែរក្រហមឡើងកាន់អំណាច។ ខ្ញុំពិតជាគ្រេកអរចំពោះការខិតខំប្រឹងប្រែងពុះពាររាល់ឧបសគ្គរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រឹងប្រែងព្យាយាមបង្រួបបង្រួមជាតិ និងស្វែងរកសន្តិភាពដល់ប្រទេសកម្ពុជារហូតដល់មានថ្ងៃនេះ។ ខ្ញុំក៏សង្ឃឹមថា ស្តូបវិមានគោលនយោបាយ ឈ្នះឈ្នះ នេះ នឹងជួយបង្ហាញពីប្រវត្តិសាស្ត្រពិតរបស់ប្រទេសកម្ពុជា ទៅកាន់យុវជន យុវនារីខ្មែរជំនាន់ក្រោយ ឲ្យធ្វើការការសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រជាតិខ្លួនឲ្យបានច្បាស់»។

ហូ ជុនា

# ព្រឹត្តិការណ៍កីឡា «ថ្មើរជើងប្រវត្តិសាស្ត្រ» លើកដំបូងនៅក្នុងស្រុកអន្លង់វែងប្រទេសកម្ពុជា

ព្រឹត្តិការណ៍កីឡា «ថ្មើរជើងប្រវត្តិសាស្ត្រ» គឺជាព្រឹត្តិការណ៍ដំបូងបង្អស់នៅក្នុងប្រទេសកម្ពុជាដែលបានរៀបចំឡើងក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ក្នុងគោលបំណងគាំទ្រដល់សន្តិភាព សន្តិសុខ និងវិបុលភាព នៅក្នុងតំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម ហើយវាក៏ជាព្រឹត្តិការណ៍សង្គមដំបូងបង្អស់ ដើម្បីប្រារព្ធខួបទី២០ឆ្នាំនៃការទទួលបានសន្តិភាពពេញលេញនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីការធ្វើសមាហរណកម្មចុងក្រោយនៅស្រុកអន្លង់វែង នៅក្នុងឆ្នាំ១៩៩៨។ ព្រឹត្តិការណ៍កីឡា «ថ្មើរជើងប្រវត្តិសាស្ត្រ» ត្រូវបានរៀបចំឡើងដោយក្រសួងទេសចរណ៍ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា រដ្ឋបាលខេត្តឧត្តរមានជ័យ សាលាស្រុកអន្លង់វែង មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការចូលរួមពីសិស្ស និស្សិត ប្រជាជន គ្រូបង្រៀន មន្ត្រីរាជការ ទាហានការពារព្រំដែន បុគ្គលិកអង្គការ សិល្បៈករខ្មែរ ព្រមទាំងសិស្ស និងទាហានថៃ និងនិស្សិតមកពីសហរដ្ឋអាមេរិកសរុបប្រមាណ ១៥០០នាក់។ ព្រឹត្តិការណ៍នេះ មានកម្មវិធីប្រគុំភ្លេងដោយក្រុមព្យុះហយាត្រាចម្រៀងនិងពិធីរាំកម្សាន្តជាមួយ ក្រុមតន្ត្រីព្រះសូរិយាផងដែរ។

ព្រឹត្តិការណ៍ថ្មើរជើងប្រវត្តិសាស្ត្រនេះត្រូវបានរៀបចំឡើងកាលពីព្រឹកថ្ងៃសៅរ៍ ទី៥ ខែមករា ឆ្នាំ២០១៩ ដោយបានចាប់ផ្តើមចេញដំណើរពីសារមន្ទីរតាម៉ុក ឆ្ពោះទៅកាន់វង្វង់មូល ទីរួមស្រុកអន្លង់វែង និងចេញដំណើរពីច្រកអន្តរជាតិជាំ ឆ្ពោះទៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង(អតីតទីបញ្ជាការរបស់ តាម៉ុក) ស្ថិតនៅលើភ្នំដងរែក ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ក្រោមអធិបតីភាពឯកឧត្តម វ៉ាត់ ចំរើន រដ្ឋលេខាធិកាក្រសួងទេសចរណ៍ និងជាអគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ឯកឧត្តម តុប សុភ័ក្តិ អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ ឯកឧត្តម ឌី រ៉ាដូ អភិបាលរងខេត្តឧត្តរមានជ័យ និងអភិបាលរងខេត្តស៊ីសាកេត ប្រទេសថៃ។

នៅក្នុងកម្មវិធីនេះ ឯកឧត្តម វ៉ាត់ ចំរើន បានមានប្រសាសន៍ថា ការចូលរួមរបស់សាធារណជនគឺជាសក្ខីភាពនៃការរួមចំណែកដល់វីរជនខ្មែរ ដែលបានតស៊ូដើម្បីទទួលបានសន្តិភាព ជូនដល់ ប្រទេសជាតិនាពេលបច្ចុប្បន្ននេះ ថែមទាំងជាការចូលរួមផ្សព្វផ្សាយកន្លែងប្រវត្តិសាស្ត្រ នៅលើភ្នំដងរែក ដើម្បីជំរុញដល់វិស័យទេសចរណ៍ប្រវត្តិសាស្ត្រ នៅតំបន់អន្លង់វែង និងជួយដល់សេដ្ឋកិច្ចដល់ប្រជាជននៅក្នុងតំបន់នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ ដែលបាន តស៊ូអត់ធ្មត់ដើរឡើងមកដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ខ្ញុំសង្ឃឹមថា កីឡាថ្មើរជើងនេះ នឹងក្លាយជាកីឡាប្រវត្តិសាស្ត្រលក្ខណៈអន្តរជាតិ និងមានការរៀបចំនៅលើទឹកដីអន្លង់វែង នៅឆ្នាំក្រោយៗទៀត។

អន្លង់វែង គឺជាស្រុកតូចមួយរបស់ខេត្តឧត្តរមានជ័យ ដែលស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ អន្លង់វែងមានព្រំដែនជាប់នឹងប្រទេសថៃ និងសម្បូណ៌ទៅដោយទីតាំងប្រវត្តិសាស្ត្រដ៏សោកសង្រេងជាច្រើនរបស់កម្ពុជា។ ខ្មែរក្រហមគឺជាឈ្មោះរបស់របបកុម្មុយនីស្តមួយ ដែលគ្រប់គ្រងប្រទេសកម្ពុជានៅក្នុងខែមេសា ឆ្នាំ១៩៧៥។ អស់រយៈពេលប្រហែល ៤ឆ្នាំក្រោយមក ប្រជាជនកម្ពុជាបានទទួលរងនូវការធ្វើការដោយបង្ខំ គ្រោះទុរ្ភិក្ស អំពើទារុណកម្មនិងការសម្លាប់រង្គាល។ នៅក្រោមរបប ប៉ុល ពត របបនេះធ្វើឲ្យប្រជាជន បាត់បង់ជីវិត និងស្ទើរតែបានបំផ្លិចបំផ្លាញមូលដ្ឋានគ្រឹះរបស់សង្គម

កម្ពុជាទាំងស្រុង ដោយរាប់ទាំងសាសនា និងវប្បធម៌។ គ្រួសារនីមួយៗត្រូវបែកខ្ញែកគ្នា មនុស្សជាទីស្រឡាញ់របស់ខ្លួនត្រូវបានបំបែក ហើយមនុស្សជាច្រើនត្រូវបានចាប់ខ្លួន និងសម្លាប់ចោល។ នៅពេលដែលរបបខ្មែរក្រហមបានដួលរលំនៅខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានគ្របដណ្តប់ទៅដោយរណ្តៅសាកសពរួមជាច្រើន។ បើទោះជារបបនេះត្រូវបានបណ្តេញចេញពីអំណាចនៅឆ្នាំ១៩៧៩ យ៉ាងណាក៏ដោយ ក៏សមាជិកខ្មែរក្រហមជាច្រើនបន្តធ្វើសង្គ្រាមទ័ពព្រៃ។ អស់រយៈពេលជិតពីរទសវត្សរ៍ ចលនាខ្មែរក្រហមបានគ្រប់គ្រងតំបន់មួយចំនួននៅក្នុងប្រទេសកម្ពុជា។ អន្លង់វែងត្រូវបានស្គាល់ថាជាតំបន់តស៊ូចុងក្រោយរបស់ចលនាខ្មែរក្រហមនេះ។ អន្លង់វែងបានបន្សល់ទុកនូវស្លាកស្នាមនៃការគ្រប់គ្រងរបស់ខ្មែរក្រហម ហើយអតីតកម្មាភិបាលជាច្រើនបន្តរស់នៅក្នុងតំបន់នេះរហូតដល់សព្វថ្ងៃនេះ។

ព្រឹត្តិការណ៍កីឡា «ថ្មើរជើងប្រវត្តិសាស្ត្រ» ព្យាយាមតម្រង់ការចាប់អារម្មណ៍ទៅលើសារសំខាន់ផ្នែកប្រវត្តិសាស្ត្ររបស់អន្លង់វែង និងទៅលើចំណុចគោលនៃសន្តិភាព សន្តិសុខ និងវិបុលភាពរបស់ប្រទេសកម្ពុជា។ អន្លង់វែងគឺជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម ប៉ុន្តែតំបន់នេះក៏ជាចំណុចរបត់និមិត្តរូបមួយនៃការងើបចេញពីអតីតកាលដ៏សោកសង្រេងរបស់កម្ពុជាដែរ។ ការធ្វើសមាហរណកម្មរបស់អន្លង់វែងមានន័យស្មើនឹងការចាប់ផ្តើមសាជាថ្មីរបស់ប្រជាជនកម្ពុជានៅក្នុងតំបន់នេះ ដែលតស៊ូជម្នះទៅនឹងសង្គ្រាម និងផលវិបាកទាំងឡាយ ដោយរាប់បញ្ចូលទាំងជំងឺ ពិការភាព ភាពក្រីក្រ និងការបាត់បង់ជីវិត។ ការធ្វើសមាហរណកម្មរបស់តំបន់នេះ ក៏មានន័យស្មើនឹងការចាប់ផ្តើមសាជាថ្មីសម្រាប់ប្រជាជនកម្ពុជាទាំងអស់គ្នាដែរ ដែលបានបញ្ចប់នូវរយៈកាលជាងបីទសវត្សរ៍នៃសង្គ្រាម អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាល។

សព្វថ្ងៃនេះ អន្លង់វែងបន្តប់នូវភាពអាថ៌កំបាំង ដំណើរ



កីឡាថ្មើរជើងប្រវត្តិសាស្ត្រចាប់ផ្តើមចេញដំណើរនៅសារមន្ទីរផ្ទះតាម៉ុកទៅកាន់រង្វង់មូលនៃស្រុកអន្លង់វែង

ផ្សងព្រេង សម្ភស្សធម្មជាតិ និងហានិភ័យខ្លះដែរ។ តំបន់នេះធ្លាប់ជាចំណុចជួរមុខនៃជម្លោះព្រំដែនជាមួយប្រទេសថៃហើយតំបន់ព្រៃស្រោងមួយចំនួននៅតែមិនអាចចូលទៅដល់ដោយសារតែគ្រាប់មីនជាដើម។ ប៉ុន្តែខណៈដែលសៀវភៅមគ្គុទ្ទេសក៍មុនៗអាចពណ៌នាអន្លង់វែង ថាជាគោលដៅនៃដំណើរផ្សងព្រេងយ៉ាងប្រថុយប្រថាន តំបន់នេះបែរជាទទួលបាននូវសុខសុវត្ថិភាព និងសន្តិភាព ដែលមិននឹកស្មានដល់។ ព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ»នេះព្យាយាមគូសបញ្ជាក់ពីតម្លៃទាំងអម្បាលមាណនេះ តាមរយៈផ្លូវដើរប្រកបដោយទេសភាពដ៏ស្រស់បំព្រងដែលបាននាំអ្នកចូលរួមក្នុងព្រឹត្តិការណ៍កីឡា «ថ្មើរជើង ប្រវត្តិសាស្ត្រ» និងសាធារណជនទាំងឡាយទៅកាន់ទីតាំងដ៏ស្រស់សោភាជាច្រើនរបស់ស្រុកអន្លង់វែង។

តំបន់នេះពោរពេញទៅដោយសម្ភស្សធម្មជាតិចម្រុះ និងសម្បូណ៍បែប ដែលអាចមើលឃើញក្នុងពេលនោះតែម្តង។ អ្នកចូលរួមក៏អាចមើលឃើញជ្រលងដងអូរតូចៗដូចម្រាមដៃ វាលស្រែស្រូវដ៏លន្លង់លន្លោច ត្រពាំងបឹងបួរដែលមានទឹកថ្លាឈ្វេង និងទឹកជ្រោះដ៏អាថ៌កំបាំងក៏មាននៅទីនោះដែរ ហើយក៏អាចមើលឃើញប្រទេសថៃពីប្រាកភ្នំប្រកបដោយទេសភាពដ៏ស្រស់ស្អាត។ ព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ»ក៏មានផ្នែកខ្លះដែលស្ថិតនៅជាប់នឹងទីតាំង និងអគារប្រវត្តិសាស្ត្ររួមមានទីបញ្ជាការ និងកន្លែងស្នាក់សំខាន់ៗរបស់មេដឹកនាំខ្មែរក្រហមទៀតផង។

ព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ»ក៏មានគោលបំណងផ្តល់ជូនសាធារណជននូវឱកាសក្នុងការធ្វើទស្សនកិច្ចនៃអតីតកាលរបស់ប្រទេសកម្ពុជា ព្រមទាំងឆ្លុះបញ្ចាំងអំពីអនាគតរបស់ប្រទេសកម្ពុជា។ តាមទស្សនៈជាច្រើនប្រទេសកម្ពុជាបានក្លាយជាទីស្មសានចំពោះអំពើអាក្រក់ទាំងឡាយ ឬមនោគមន៍វិជ្ជា ភាពជាសត្រូវនិងយុទ្ធសាស្ត្រដែលបរាជ័យ។ ប៉ុន្តែ បើទោះជាជម្លោះនិងភាពត្រដាបត្រដួសនៅក្នុងប្រវត្តិសាស្ត្រក៏ដោយ ប្រទេសកម្ពុជាតំណាងឲ្យទឹកដីនៃសេចក្តីសង្ឃឹម និងឱកាស។ ព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ»នេះបាន និងកំពុងជំរុញទឹកចិត្តឲ្យមានព្រឹត្តិការណ៍កីឡា«ថ្មើរជើងប្រវត្តិសាស្ត្រ»សម្រាប់ជាការឆ្លុះបញ្ចាំង និងដើរឆ្ពោះទៅកាន់ផ្ទះរបស់ ប៉ុល ពត ដែលជាការស្តែងឲ្យឃើញជានិមិត្តរូបនៃសមត្ថភាពរបស់ប្រជាជនកម្ពុជាទាំងអស់ក្នុងការរៀនសូត្រ និងតស៊ូជម្នះទៅនឹងអតីតកាលរបស់ខ្លួន។ ខណៈដែលយើងមិនអាចគេចចេញពីប្រវត្តិសាស្ត្ររបស់យើង យើងក៏មិនត្រូវក្លាយជាទាសកររបស់ប្រវត្តិសាស្ត្រដែរ។ មានតែការរៀនសូត្រពីអតីតកាលតែប៉ុណ្ណោះទេ ទើបយើងអាចមានសេចក្តីសង្ឃឹមក្នុងការបោះជំហានទៅមុខតទៅទៀតបាន។

ចាំង ស៊ីវ៉ាត់ អាយុ៣៥ឆ្នាំ គឺជាប្រជាជនដែលរស់នៅនិងធ្វើការនៅក្នុងតំបន់អន្លង់វែងបានឲ្យដឹងថា «ព្រឹត្តិការណ៍កីឡាថ្មើរជើងប្រវត្តិសាស្ត្រនេះ ពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជនកម្ពុជាទូទាំងប្រទេស»។ «ព្រឹត្តិការណ៍កីឡានេះ នឹងជួយទាក់ទាញ និងបង្ហាញដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ជាពិសេសអ្នកសិក្សាស្រាវជ្រាវដែលចង់ស្វែងយល់អំពីប្រវត្តិសាស្ត្រដ៏សាហាវយង់ឃ្នងដែលធ្លាប់បានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំគិតថា ប្រជាជនជាច្រើននឹងស្គាល់តំបន់អន្លង់វែង តាមរយៈព្រឹត្តិការណ៍កីឡាថ្មើរជើងប្រវត្តិសាស្ត្រនៅថ្ងៃនេះ។ ខ្ញុំក៏សង្ឃឹមផងដែរថា ព្រឹត្តិការណ៍ថ្មើរជើងប្រវត្តិសាស្ត្រ នឹងរៀបចំឡើងនៅឆ្នាំក្រោយៗជាបន្តទៀត ដើម្បីឲ្យសាធារណជនទូទៅស្គាល់តំបន់ប្រវត្តិសាស្ត្រអន្លង់វែងកាន់តែច្បាស់។

ម៉ក់ សីហា ជាសិស្សមកពីវិទ្យាល័យអន្លង់វែងបានឲ្យដឹងថា ខ្ញុំពិតជាសប្បាយរីករាយដែលបានចូលរួមកម្មវិធីថ្មើរជើងប្រវត្តិសាស្ត្រនេះ ព្រោះបានធ្វើស្រុកអន្លង់វែងមានមនុស្សស្គាល់ច្រើន និងក្លាយជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រដ៏ទាក់ទាញ។ ប្រសិនបើមានកម្មវិធីនេះនៅឆ្នាំក្រោយៗទៀត ខ្ញុំនឹងមកចូលរួម ហើយខ្ញុំក៏សំណូមពរឲ្យមានការរៀបចំកម្មវិធីថ្មើរជើងប្រវត្តិសាស្ត្រ នៅលើទឹកដីស្រុកអន្លង់វែងរៀងរាល់ឆ្នាំដែរ។

*សោម ប៊ុនថន និង ហូ ថុនា*

# ខួប២០ឆ្នាំនៃការចុះចូលរបស់ នួន ជា និង ខៀវ សំផន ដែលឈានទៅរកការបញ្ចប់សង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជា

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ឆ្នាំនេះ គឺជាខួប២០ឆ្នាំនៃការចុះចូលរបស់ នួន ជា និង ខៀវ សំផន ជាមួយរាជរដ្ឋាភិបាលកម្ពុជា។

នួន ជា គឺជាអតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជន។ ខៀវ សំផន គឺជាអតីតគណៈប្រធានរដ្ឋ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។ អ្នកទាំងពីរ បានរត់ភៀសខ្លួនទៅរស់នៅតាមបណ្តោយព្រំដែនខ្មែរ-ថៃក្នុងខេត្តកោះកុង ខេត្តពោធិ៍សាត់និងខេត្តបាត់ដំបង បន្ទាប់ពីកងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានវាយផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យនៅដើមឆ្នាំ១៩៧៩។ នៅទីនោះ នួន ជា និង ខៀវ សំផន បានបន្តដឹកនាំ និងអនុវត្តការងារសំខាន់ៗជាច្រើន ដូចជា កិច្ចការសេដ្ឋកិច្ច កិច្ចការបរទេស ការបណ្តុះបណ្តាលផ្នែកនយោបាយ គោលនយោបាយ និងឃោសនា។ ចំណែកមេដឹកនាំខ្មែរក្រហមផ្សេងទៀត បានប្រមូលកម្លាំងទ័ពដែលនៅសេសសល់របស់ខ្លួនឡើងវិញ និងបានរៀបចំគ្រប់គ្រងទឹកដីកម្ពុជាដែលនៅសេសសល់ដោយបានបង្កើតទៅជាភូមិ សាលារៀន និងប្រព័ន្ធសុខាភិបាល។ មេដឹកនាំយោធាខ្មែរក្រហម ក៏បានរៀបចំធ្វើសង្គ្រាមឈ្លប ឬសង្គ្រាមប្រជាជន ដើម្បីប្រយុទ្ធប្រឆាំងជាមួយកងទ័ពវៀតណាម និងរបប



កងកម្លាំងខ្មែរក្រហមដែលនៅសេសសល់ប្រមាណជិតពីរពាន់នាក់នៅស្រុកអន្លង់វែង បានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ក្រោមអធិបតីភាពរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិឯកឧត្តម ទៀ បាញ់ និង ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សេរីរ័ត្ន។

សាធារណរដ្ឋប្រជាមានិតកម្ពុជាដែរ។

នៅពេលដែលកងយោធពលខេមរភូមិន្ទ បានវាយកាន់កាប់ទីបញ្ជាការរបស់ខ្មែរក្រហមនៅភ្នំឆ័ត្រ ក្នុងស្រុកស្វាយចេក ជាប់នឹងព្រំដែនថៃ នៅឆ្នាំ១៩៩៣ ខៀវ សំផន បានរត់ភៀសខ្លួនមកស្រុកអន្លង់វែង ដែលគ្រប់គ្រងដោយ តាម៉ុក អគ្គបញ្ជាការកងទ័ពបន្ទាប់ពី ប៉ុល ពត (មេបញ្ជាកងទ័ព) នៅក្នុងរចនាសម្ព័ន្ធយោធាថ្មីរបស់ខ្មែរក្រហម ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៦។ នួន ជា បានផ្លាស់មករស់នៅអន្លង់វែង នៅខែតុលា ឆ្នាំ១៩៩៦បន្ទាប់ពីខ្មែរក្រហមនៅម៉ាឡៃ ប៉ៃលិននិងសមរភូមិទិស២៥០ រួមមាន ស្រុកសំពៅលូន ភ្នំព្រឹក្ស និងកំរៀង បានផ្ដាច់ខ្លួនចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា។ តាម៉ុក បានសង់ផ្ទះឲ្យ នួន ជា ខៀវ សំផន និងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនទៀតស្នាក់នៅត្រង់ម្តុំពើយតាម៉ុក ក្បែរប្រេកព្រំដែនជាំស្រង៉ុំ។

រហូតមកដល់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៤ រដ្ឋសភានៃរាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ «ដាក់ឲ្យក្រុមខ្មែរក្រហមនៅក្រៅច្បាប់» និងចូលជាធរមាននៅថ្ងៃទី១៥ កក្កដា ឆ្នាំដដែល ដែលច្បាប់នេះបានផ្តោតទៅលើតែមេដឹកនាំខ្មែរក្រហមនិងកងទ័ពខ្មែរក្រហមតែប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលប្រជាជនសាមញ្ញដែលរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមឡើយ។ នៅក្រោមច្បាប់នេះ អង្គការខ្មែរក្រហមត្រូវបានចាត់ទុកថាជាអង្គការខុសច្បាប់ ហើយមេដឹកនាំខ្មែរក្រហមអាចប្រឈមនឹងការកាត់ទោសឲ្យជាប់គុកពី១០ឆ្នាំ ទៅមួយជីវិត។ ជាការឆ្លើយតបទៅនឹង ច្បាប់នេះ ខ្មែរក្រហមបានប្រកាសបង្កើតរដ្ឋាភិបាលបង្រួមបង្រួមជាតិ និងសាមគ្គីជាតិកម្ពុជា ដែលមានទីស្នាក់ការនៅក្នុងស្រុកអន្លង់វែង។ សមាជិករដ្ឋាភិបាលបណ្តោះអាសន្ននេះ រួមមាន ខៀវ សំផន នាយករដ្ឋមន្ត្រី, ចាន់ យូរ៉ាន់ ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេស, កែវ យ៉ាន រដ្ឋមន្ត្រីការពារជាតិ, ម៉ក់ បេន រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ជួន ជឿន ទីប្រឹក្សាពិសេស, ទេព យុនណាល់ រដ្ឋមន្ត្រីទទួលបន្ទុកបូរណភាពទឹកដី, យឹម ផន រដ្ឋមន្ត្រីមហាផ្ទៃ, គោរ ប៊ុនហេង រដ្ឋមន្ត្រីកិច្ចការធារណៈ និង តាម៉ុក អគ្គមេបញ្ជាការ។

នួន ជា, សុន សេន និង ប៉ុល ពត មិនមានឈ្មោះនៅក្នុងបញ្ជីមេដឹកនាំរដ្ឋាភិបាល បណ្តោះអាសន្នរបស់ខ្មែរក្រហមនោះទេ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ប៉ុល ពត នៅតែជាមេដឹកនាំដ៏មានអំណាច និងមានឥទ្ធិពលមួយរូបនៅក្នុងរដ្ឋាភិបាលបណ្តោះអាសន្ននេះ។ នួន ជា នៅតែដើរតួនាទីជាអ្នកអប់រំ។ នួន ជា បានផ្តល់ការអប់រំដល់កងទ័ព និងកម្មាភិបាលខ្មែរក្រហមជាប្រចាំ។ នួន ជា ក៏បានអប់រំណែនាំដល់ប្រជាជន អំពីប្រធានបទស្តីអំពីជីវិតរស់នៅប្រចាំថ្ងៃ ដូចជា ការថែរក្សាអនាម័យ ចិញ្ចឹមសត្វ និង ការប្រុងប្រយ័ត្នចំពោះជំងឺគ្រុនចាញ់។ ចំណែកកិច្ចការសំខាន់របស់ នួន ជា មួយទៀត គឺការអប់រំអំពីមនោគមន៍វិជ្ជានយោបាយកុំឲ្យប្រជាជនបោះបង់ចោលការតស៊ូ និងត្រូវលះបង់ដើម្បីបុព្វហេតុជាតិ។

ទោះបីយ៉ាងនេះក្តី មេដឹកនាំខ្មែរក្រហមដែលប្រមូលផ្តុំគ្នានៅអន្លង់វែង មិនមានគំនិតចុះសម្រុងគ្នាឡើយក្នុងការបន្តដឹកនាំចលនាតស៊ូប្រឆាំងនឹងរាជរដ្ឋាភិបាលកម្ពុជា។ នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៧ ប៉ុល ពត បានបញ្ជាទៅ សូ សារឿន មេបញ្ជាយោធាខ្មែរក្រហមដែលស្និទ្ធនឹងខ្លួនឲ្យទៅសម្លាប់ សុន សេន ប្រពន្ធ ព្រមទាំងកូនៗ នៅផ្ទះម្តុំពើយតាម៉ុក ស្ថិតនៅលើភ្នំដងរែក ដោយចោទថាក្បត់។ ការស្លាប់របស់ សុន សេន និងក្រុមគ្រួសារបានធ្វើឲ្យ តាម៉ុក ខឹងក្រេវក្រោធយ៉ាងខ្លាំង និងបានប្រមូលកម្លាំងស្មោះស្ម័គ្រនឹងខ្លួនវាយទៅលើ ប៉ុល ពត វិញ។ នៅអំឡុងពេលនោះ តាម៉ុក បានឃោសនាឲ្យមានការប្រឆាំងនឹងការដឹកនាំរបស់ ប៉ុល ពត និងបានអំពាវនាវដល់ប្រជាជនឲ្យចូលរួមជាមួយខ្លួន។ ឆ្លើយតបទៅនឹងការឃោសនានេះ ប៉ុល ពត បានវាយប្រហារ តាម៉ុក និងកងកម្លាំងរបស់ តាម៉ុក តាមវិទ្យុ ដោយបានចោទថា ក្បត់ជាតិ។

ខៀវ សំផន ក៏បានចូលរួមក្នុងជម្លោះនោះដែរ។ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៧ ខៀវ សំផន បានអានសេចក្តីប្រកាស

របស់ ប៉ុល ពត តាមវិទ្យុដោយបានចោទប្រកាន់ សុន សេន ថាក្បត់នឹងចលនា និងជាភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់រដ្ឋាភិបាល នៅទីក្រុងភ្នំពេញ។

បន្ទាប់ពីការប្រយុទ្ធគ្នារយៈពេល៥ថ្ងៃ ប៉ុល ពត, នួន ជា, ខៀវ សំផន ក៏បានរត់គេចខ្លួនពីកងកម្លាំងរបស់ តាម៉ុក។ នៅទីបញ្ចប់ ប៉ុល ពត ត្រូវបានយោធារបស់ តាម៉ុក ចាប់ខ្លួនពីកន្លែងលាក់ខ្លួននៅក្នុងជួរភ្នំ និងសែងត្រឡប់មកវិញ។ នួន ជា និង ខៀវ សំផន បានដើរដោយថ្មើរជើង។ នួន ជា និង ខៀវ សំផន បានយំនៅពេលដើរតាមផ្លូវត្រឡប់មកវិញ ព្រោះខ្លាច តាម៉ុក សម្លាប់ចោល។ ក្រោយមកអ្នកទាំងពីរត្រូវបានដោះលែងវិញ លើកលែងតែ ប៉ុល ពត និងមេបញ្ជាការយោធាមួយចំនួនទៀត ត្រូវបានបញ្ជូនទៅឃុំឃាំងក្បែរច្រកព្រំដែនជាំស្រងុំ។ ដោយសារគ្មានកន្លែងត្រូវទៅ នួន ជា និង ខៀវ សំផន បានបន្តរស់នៅជាមួយ តាម៉ុក។

មួយរយៈក្រោយមកមេបញ្ជាការយោធារបស់ តាម៉ុក មួយក្រុមបានរៀបចំផែនការផ្តាច់ខ្លួនចុះចូលជាមួយរដ្ឋាភិបាលនៅភ្នំពេញ ជាសម្ងាត់ដោយមិនឲ្យ តាម៉ុក ដឹងឡើយ។ មេបញ្ជាការខ្មែរក្រហមទាំងនោះបានស្នើសុំបីចំណុចទៅសម្តេច ហ៊ុន សែន គឺ ទី១) សិទ្ធិរស់នៅជាប្រជាជនសាមញ្ញ ទី២) សិទ្ធិក្នុងការកាន់កាប់កម្មសិទ្ធិឯកជន និងសិទ្ធិក្នុងការគ្រប់គ្រងរដ្ឋបាលក្នុងតំបន់ និង ទី៣) សិទ្ធិក្នុងការទទួលបានតួនាទីក្នុងជួររដ្ឋាភិបាលនៅក្នុងតំបន់ដែលខ្លួនធ្លាប់គ្រប់គ្រង។

បន្ទាប់មកការវាយប្រយុទ្ធគ្នាមួយបានផ្ទុះឡើងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៧ រវាងក្រុមដែលរៀបចំផ្តាច់ខ្លួន និងកម្លាំងដែលស្មោះត្រង់ជាមួយ តាម៉ុក។ ការប្រយុទ្ធគ្នាបានបន្តរហូតដល់ខែមីនា ឆ្នាំ១៩៩៨ តាម៉ុក ក៏បានដឹកនាំកងទ័ព និងមេដឹកនាំខ្មែរក្រហម រួមមាន នួន ជា ខៀវ សំផន និង ប៉ុល ពត ឆ្លងចូលទៅដីថៃ។

នៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៩៨ កងទ័ពរបស់ តាម៉ុក បានវាយដណ្តើមអន្លង់វែងវិញ ប៉ុន្តែមិនយូរប៉ុន្មានកងទ័ពរបស់ តាម៉ុក ត្រូវបានបណ្តេញចេញពីអន្លង់វែង ដោយកងកម្លាំងយោធាខ្មែរក្រហមដែលផ្តាច់ខ្លួនរួមនឹងកងយោធពលខេមរភូមិន្ទ។

នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៩៨ ភាគីទាំងសងខាងបានឈានដល់ការព្រមព្រៀងគ្នាបញ្ចប់ជម្លោះ និងរំលាយកងទ័ពខ្មែរក្រហមដែលនៅសេសសល់។ ចំណែក តាម៉ុក ក៏យល់ព្រមចុះចាញ់ និងអនុញ្ញាតឲ្យកងទ័ព និងប្រជាជនទាំងអស់ចុះពីលើភ្នំ។

រហូតមកដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៨ នួន ជា និង ខៀវ សំផន ក៏បានយល់ព្រមចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ៥ថ្ងៃក្រោយមក គឺនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ដដែល នួន ជា និង ខៀវ សំផន បានឡើងមកជួប និងទទួលបានការស្វាគមន៍ពីសម្តេច ហ៊ុន សែន យ៉ាងកក់ក្តៅនៅភូមិគ្រឹះរបស់សម្តេចក្នុងក្រុងតាខ្មៅ ខេត្តកណ្តាល។ បន្ទាប់ពីការចុះចូល នួន ជា និង ខៀវ សំផន ត្រូវបានអនុញ្ញាតឲ្យរស់នៅដោយសេរីនៅប៉ៃលិន។ ការចុះចូលរបស់ នួន ជា និង ខៀវ សំផន គឺជាការបញ្ចប់សង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជា ហើយពិធីសមាហរណកម្មជាផ្លូវការត្រូវបានប្រារព្ធធ្វើឡើងនៅស្រុកអន្លង់វែង នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ក្រោមអធិបតីភាពរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិឯកឧត្តម ទៀ បាញ់ និង ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សេរីរ័ត្ន។

នួន ជា និង ខៀវ សំផន បានរស់នៅប៉ៃលិន រហូតត្រូវបានចាប់ខ្លួនយកមកឃុំឃាំងបណ្តោះអាសន្ននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅឆ្នាំ២០០៧ ជាមួយបទចោទប្រកាន់ពីការប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។ បន្ទាប់ពីចំណាយពេល១១ឆ្នាំ ក្នុងការជំនុំជម្រះក្តី ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នេះ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រេចចោទប្រកាន់ នួន ជា និង ខៀវ សំផន ស្តីពីបទប្រព្រឹត្ត ១)ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ២)ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ៣) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបានផ្តន្ទាទោសអ្នកទាំងពីរឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ **សោម ប៊ុនថន**

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

(តពីលេខមុន)

យឹម អន ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទ នៃការបញ្ជូនមកដល់ទួលស្លែង និងការសម្លាប់នៅឡើយ។

យឹម យុន ហៅ ផាត ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅពាណិជ្ជកម្មរដ្ឋ។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការបញ្ជូនមកដល់ទួលស្លែង និងការសម្លាប់នៅឡើយ។

យឹម ផល្លា ហៅ ហ៊ឹម មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅក្រូចឆ្មារ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំខ្លុងនិងអ៊ំស្រីស្រ៊ុនអនុនយោធាយវរៈសេនាតូចកងពល៤៥០ មានប្រពន្ធឈ្មោះ សេង ហាក់ ហៅ ជឿន មានកូនប្រុស២នាក់ និងស្រី៤នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកងពល៤៥០ ហើយបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃបន្ទាប់។ ខ្មែរក្រហមសម្លាប់ យឹម ផល្លា នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៣៤ ថ្ងៃ។

យី ហេង ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការបញ្ជូនមកដល់ទួលស្លែង និងការសម្លាប់នៅឡើយ។

យឹម អន ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការបញ្ជូនមកដល់ទួលស្លែង និងការសម្លាប់នៅឡើយ។

យឹម យុន ហៅ ផាត ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅពាណិជ្ជកម្មរដ្ឋ។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការបញ្ជូនមកដល់ទួលស្លែង និងការសម្លាប់នៅឡើយ។

យឹម ផល្លា ហៅ ហ៊ឹម មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅក្រូចឆ្មារ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំខ្លុងនិងអ៊ំស្រីស្រ៊ុនអនុនយោធាយវរៈសេនាតូចកងពល៤៥០ មានប្រពន្ធឈ្មោះ សេង ហាក់ ហៅ ជឿន មានកូនប្រុស២នាក់ និងស្រី៤នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកងពល៤៥០ ហើយបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃបន្ទាប់។ ខ្មែរក្រហមសម្លាប់ យឹម ផល្លា នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៣៤ ថ្ងៃ។

យឹម យុទ្ធ ហៅ ស៊ីម ជាពេទ្យកម្មករកំពង់សោម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោមក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការបញ្ជូនមកដល់ទួលស្លែង និងការសម្លាប់នៅឡើយ។

យឹម សាន មានអាយុ៥៤ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅតានី ខេត្តកំពត ជាកូនរបស់លោកតា អ៊ុក យឹម និងលោកយាយសីខែជាប្រជាជនចាស់មានប្រពន្ធឈ្មោះនួន សារិន មានកូនប្រុស៣នាក់ និងស្រី៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ នៅស្រែអំបិលរដ្ឋ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ៤បន្ទប់តូច ១។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ខ្មែរក្រហមបញ្ជូន យឹម សាន មកដល់គុកទួលស្លែង នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយបែរជាសម្លាប់នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៦ ទៅវិញ។

ឃឹម សាបូ កងហាននៃកងពល ២៩០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ២៩០ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូល ឃឹម សាបូ មកគុកទួលស្លែងនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ១៤ ថ្ងៃ។

ឃឹម សារុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការបញ្ជូនមកដល់ទួលស្លែង និងការសម្លាប់នៅឡើយ។

ឃឹម សិត ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការបញ្ជូនមកដល់ទួលស្លែង និងការសម្លាប់នៅឡើយ។

ឃឹម ឡុំ មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក២០ តំបន់ ៣១ ជាកូនរបស់ពូ លន និងមីង គុន ជាយុទ្ធជនកងពល៥០២ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកងពល៥០២។ ខ្មែរក្រហមសម្លាប់ ឃឹម ឡុំ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ២៨ថ្ងៃ។

ឃឹន ផាត ហៅ ហាក់ កងហាក្នុងកងពល ៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅកងពល៣១០។ ខ្មែរក្រហមបញ្ជូល ឃឹន ផាត មកគុកទួលស្លែងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ៣៤ ថ្ងៃ។

យុត ឈឿន ហៅ គ្រាន មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់ពូ យុត ចិន និងមីង អាន យោធាវរៈសេនាតូចកងពល៣១០ មានប្រពន្ធឈ្មោះ លាប ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកងពល៣១០ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ង បន្ទប់ធំ ០៣ បន្ទប់តូច ១០។ ខ្មែរក្រហមសម្លាប់ យុត ឈឿន នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ១៣១ថ្ងៃ។

យុត ធីន មានអាយុ១៧ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅទូកមាស ខេត្តកំពត ជាកូនរបស់ពូ សន និង មីង នីង សាទ ជាយុទ្ធជនមន្ទីរពិការ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦ នៅពេទ្យសេនាធិការ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ដ បន្ទប់ធំ ៣ បន្ទប់តូច ១៧ នៅថ្ងៃបន្ទាប់។ ខ្មែរក្រហមសម្លាប់ យុត ធីន នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ១៣០ ថ្ងៃ។

យុត រុន មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក ៥៩ តំបន់ ៣៣ (ស្រុកព្រៃកប្បាសខេត្តតាកែវ) ជាកូនរបស់ពូ ចាន យន និងមីង ម៉ែន អ៊ុម យុទ្ធជន ១២៧ កងពល៧០៣ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧ នៅកងពល៧០៣ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ដ បន្ទប់ធំ ៥ បន្ទប់តូច ៤។ ខ្មែរក្រហមសម្លាប់ យុត រុន នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ៦៧ ថ្ងៃ។

យុត ឡុំ ហៅ រើម មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅសូទ្រនិគម ខេត្តសៀមរាប ជាកូនរបស់ពូ យុត នែម និងមីង ដឹម វ៉ាត លេខាធនុសេនាធំកងពល៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៥ខែមករា ឆ្នាំ១៩៧៧ នៅកងពល៣១០។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

យុន ចាន់ស៊ីថា ហៅ យៀង ហៅ យុន ចាន់ស៊ីថាត មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់ពូ យុន ហួត និងមីង ឆាយ ឈៀង យុទ្ធជនវរៈ៧៧២ ភូមិភាគខគ្គរ មានប្រពន្ធឈ្មោះ អ៊ិន គីមសៀន ហៅ ជៀន មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៦ នៅពាណិជ្ជកម្ម ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ៥ បន្ទប់តូច ៤ នៅថ្ងៃដដែល។ ខ្មែរក្រហមសម្លាប់ យុន ចាន់ស៊ីថា នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ១៥២ ថ្ងៃ។ (តលេខក្រោយ)

# ហ៊ុយ ម៉ាន់ ៖ ពលទាហាន

ប្រពន្ធរបស់ ហ៊ុយ ម៉ាន់ ឈ្មោះ ផុន សំអាន បាននិយាយរៀបរាប់រឿងរ៉ាវប្រាប់ថា ៖

ខ្ញុំមិនទាន់មានស្នេហាពិតប្រាកដនៅឡើយទេ នៅពេលដែលខ្ញុំអាយុបាន១៨ឆ្នាំ។ ម៉ាន់ និងខ្ញុំបានជួបគ្នានាថ្ងៃចូលឆ្នាំខ្មែរ នៅពេលដែលគាត់ឈប់សម្រាករយៈពេលខ្លីពីកងទ័ព។ វាជាស្នេហាលើកដំបូងសម្រាប់គាត់។ នៅពេលដែលគាត់បាននាំប្រធានអង្គភាពរបស់គាត់ទៅស្នើម្ដាយខ្ញុំសុំខ្ញុំរៀបការ ខ្ញុំមិនមានអារម្មណ៍ស្រឡាញ់គាត់ទេ។ ប៉ុន្តែខ្ញុំបានយល់ព្រមតាមការរៀបចំរបស់ឪពុកម្ដាយខ្ញុំ។ ចៅហ្វាយរបស់គាត់ និងលោក ឡាយ សំ វរសេនីយ៍ឯកនៅអង្គភាព៥៥៤ បានចូលរួមពិធីមង្គលការរបស់ខ្ញុំ ប៉ុន្តែមិនមែនជាឪពុកម្ដាយរបស់ម៉ាន់ ទេ។

នៅចន្លោះឆ្នាំ១៩៧២ និងឆ្នាំ១៩៧៣ ប្រជាជនបានភៀសខ្លួនចេញពីភូមិរបស់យើងនៅក្នុងខេត្តកណ្ដាល ព្រោះប្រជាជនមិនចង់ចូលរួមជាមួយខ្មែរក្រហម។ គ្រួសាររបស់ខ្ញុំបានផ្លាស់ទៅរស់នៅក្នុងបន្ទាយទាហានរបស់ប្ដីខ្ញុំ ជាទីកន្លែងដែលទាហានអាមេរិកបានចែកស្បៀងអាហារឲ្យយើង។

ជាភរិយារបស់ទាហានម្នាក់ មានការលំបាកយ៉ាងខ្លាំងនៅពេលនោះ។ ខ្ញុំបានវេចខ្ចប់ អាហារដាក់ក្នុងប្រអប់ស្ព័កគ្នោត ហើយយកទៅឲ្យប្ដីរបស់ខ្ញុំនៅលើសមរភូមិប្រយុទ្ធ ទោះជាគាត់បានប្រាមខ្ញុំកុំឲ្យប្រថុយប្រថានជីវិតធ្វើដូច្នេះក៏ដោយ។ យោធាខ្មែរក្រហមបានចូលមកកាន់តែកៀក ទាហាន លន់ នល់ បានបាត់បង់ភាពក្លាហានរបស់ខ្លួន និងបានលើកទង់ជ័យស ដោយដឹងថាខ្លួនមិនអាចឈ្នះខ្មែរក្រហម។ បន្ទាប់មក ម៉ាន់ បានត្រឡប់មកផ្ទះជួបខ្ញុំ និងកូនៗ។

គ្រួសាររបស់ខ្ញុំបានព្យាយាមចេញទៅក្រុងភ្នំពេញ នៅ



ហ៊ុយ ម៉ាន់



ផុន សំអាន នៅថ្ងៃពិធីមង្គលការរបស់នាង នៅឆ្នាំ១៩៧២

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប៉ុន្តែយើងមិនត្រូវបានអនុញ្ញាតឲ្យចូលទីក្រុងឡើយ ខ្មែរក្រហមបាននិយាយថា កងទ័ពអាកាសរបស់អាមេរិក នឹងមកទម្លាក់គ្រាប់បែកនៅទីនោះក្នុងពេលឆាប់ៗនេះ។ ឪពុករបស់ខ្ញុំចង់ត្រឡប់ទៅស្រុកកំណើតរបស់គាត់យ៉ាងខ្លាំង គាត់ជាបុរសម្នាក់មានការអប់រំ និងគិតថាខ្មែរក្រហមនឹងឲ្យឋានៈ និងការងារមួយនៅទីនោះ។ គាត់បានសួរអ្នកភូមិខ្លះ ប្រសិនបើយើងអាចទៅជាមួយគេតាមរថយន្តធំៗ ខ្ញុំបាននិយាយទៅគាត់ថា «ប៉ា វាមិនប្រើពេលយូរទេ បើដើរទៅកាន់ស្រុកកំណើតរបស់យើង។ ប្រសិនបើប៉ាចង់ទៅតាមរថយន្តធំ ទៅតែម្នាក់ឯងទៅ» ឪពុករបស់ខ្ញុំ ខឹងនឹងខ្ញុំយ៉ាងខ្លាំង និងអ្នកផ្សេងទៀតនៅក្នុងគ្រួសាររបស់ខ្ញុំ ដែលមិនស្តាប់គាត់។ គាត់បានឡើងរថយន្តធំនោះ ប៉ុន្តែរថយន្តនោះបែរជាចេញឆ្ពោះទៅខេត្តបាត់ដំបងវិញ។ ការប៉ងប្រាថ្នារបស់ប៉ាខ្ញុំមិនបានសម្រេច ហើយគាត់បានបាត់ខ្លួនរហូត។

នៅក្នុងសហករណ៍ កូនស្រីរបស់ខ្ញុំម្នាក់អាយុបានមួយឆ្នាំ បានហូបរបស់រឹងបណ្តាលឲ្យវា រាកមួលមិនឈប់ឈរ។ ខ្ញុំក៏បានយកវាទៅមន្ទីរពេទ្យ។ ម្តាយរបស់ខ្ញុំឈ្មោះ អ៊ិម ប៉ុក បានផ្លាស់វេនគ្នានៅកំដរនាង។ ពេទ្យបានចាក់ថ្នាំឲ្យកូនស្រីខ្ញុំ ម្តាយខ្ញុំបាននិយាយថា កូនស្រីខ្ញុំបានស្លាប់យ៉ាងអណោចអធ័ម។ គាត់ចង់កប់សាកសពចៅស្រីរបស់គាត់ ប៉ុន្តែគ្រូពេទ្យក្មេងម្នាក់បានយកសពរបស់នាងចេញទៅ ហើយមិនអនុញ្ញាតឲ្យម្តាយខ្ញុំទៅតាមឡើយ។ នៅពេលដែលខ្ញុំបានដឹងថាកូនស្រីខ្ញុំស្លាប់ ខ្ញុំរត់ទៅមន្ទីរពេទ្យ ប៉ុន្តែពេលខ្ញុំទៅដល់ វាយឺតពេលហើយ។ នៅថ្ងៃនោះ របបបបររបស់ខ្ញុំបានឲ្យទៅអ្នកផ្សេងទៀត។

ស្រូវនៅក្នុងភូមិយើងបានហូបអស់មិនដល់មួយឆ្នាំផង ហើយគ្រួសាររបស់យើងក៏បានបែកគ្នា។ នៅពេលខ្លះយើងអាចជួបជុំគ្នា ហើយប្តីរបស់ខ្ញុំគាត់តែងតែព្យាយាមទៅរកស្បៀងសម្រាប់គ្រួសារ។

ម៉ាន់ មិនចេះហែលទឹកទេ។ នាពេលមួយនោះ គាត់បានប្រថុយជីវិតរបស់គាត់ឆ្លងស្ទឹង នៅអំឡុងរដូវវស្សាទៅរកបន្លែខ្លះសម្រាប់គ្រួសារយើងហូប។ គាត់ស្ទើរតែលង់ទឹកស្លាប់ ប៉ុន្តែប្អូនប្រុសពៅរបស់គាត់បានជួយគាត់ទាន់ពេល។ ទោះបីជាយ៉ាងណាក៏ដោយ គាត់បានប្រឹងប្រែងយ៉ាងអស់ពីសមត្ថភាពរបស់គាត់ ដោយទទួលបានអំបិលមួយក្រឡធំ និងឯកសណ្ឋានយោធាពីរពីអ្នកភូមិដែលមានចិត្តល្អ។

ខ្ញុំតែងតែអះអាងថា ប្តីរបស់ខ្ញុំជាកសិករក្រីក្រម្នាក់ នៅពេលដែលខ្មែរក្រហមបានសួរអំពីប្រវត្តិរូបរបស់គាត់។ ប៉ុន្តែការរក្សាការសម្ងាត់នេះមិនអាចលាក់បាំងបានឡើយចំពោះអង្គការ ដែលមានបណ្តាញច្រើន ដែលបានស៊ើបសួរនាំអ្នកភូមិផ្សេងអំពីប្តីរបស់ខ្ញុំ។ នៅខែកក្កដា ឆ្នាំ១៩៧៧ គាត់ត្រូវបានបញ្ជូនឲ្យទៅកាប់ឈើ។ នៅពេលដែលគាត់ចេញទៅ គាត់និយាយថា «ប្រសិនបើខ្ញុំមិនត្រឡប់មកវិញក្នុងរយៈពេលពីរទៅបីថ្ងៃទៀត ខ្ញុំប្រហែលជាត្រូវបានចាប់ខ្លួន ឬធ្វើទារុណកម្មដោយយោធាខ្មែរក្រហមហើយ។ ប្រសិនបើវាមានរឿងកើតឡើងដូច្នេះមែន ខ្ញុំនឹងធ្វើអត្តឃាត។ សូមជួយមើលថែរក្សាកូនៗរបស់យើងឲ្យបានល្អផង»។ នៅពេលនោះខ្ញុំបានពរពោះ ៧ខែ។ មួយអាទិត្យក្រោយមក ខោអាវរបស់គាត់បានយកមកភូមិវិញ ឲ្យអ្នកភូមិផ្សេងទៀតស្លៀកពាក់។ ខ្ញុំស្គាល់ខោអាវទាំងនោះ ព្រោះអីខ្ញុំបានដេរដោយផ្ទាល់ដៃរបស់ខ្ញុំ។ ពីរខែនិងប្រាំថ្ងៃបន្ទាប់ពីប្តីរបស់ខ្ញុំបានចាប់យកទៅ ខ្ញុំឆ្លងទន្លេបានកូនប្រុសមួយទៀត។

ខ្មែរក្រហមប៉ិះតែនឹងសម្លាប់ខ្ញុំ ព្រោះខ្ញុំចង់ដឹងដំណឹងពីប្តីរបស់ខ្ញុំ។ ខ្ញុំបានសួរប្រធានកង «នៅពេលណាប្តីរបស់ខ្ញុំត្រឡប់មកផ្ទះវិញ?»។ អ្នកភូមិបានខ្សឹបប្រាប់ថា សមមិត្តអាន នឹងបញ្ជូនខ្ញុំឲ្យទៅរស់នៅជាមួយប្តីរបស់ខ្ញុំ ប្រសិនបើខ្ញុំបន្តសួរដូច្នេះ។ អ្នកមូលដ្ឋានម្នាក់ឈ្មោះ លឿង បានប្រាប់ខ្ញុំថា កុំឲ្យសួរអំពីប្តីរបស់ខ្ញុំទៀត ខ្ញុំអាចនឹងត្រូវសម្លាប់ ហើយបានប្រាប់ថា ម៉ាន់ ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស្អាង។ បន្ទាប់ពីនោះមក ខ្ញុំមិនហ៊ានសួរទៀតឡើយ។

នៅពេលដែលរបបខ្មែរក្រហមបានដួលរលំទៅ ខ្ញុំមានសំណាងណាស់ដែលនៅរស់រានមានជីវិត។

**ប៉ាង ពីរ័ន្ត និង វេនី ខកហ្គៀល**

# អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ

## បញ្ជីអដ្ឋិធាតុដែលរកឃើញនៅក្រោមបល្ល័ង្កព្រះពុទ្ធរូបក្នុងវត្តលង្កា, ទីក្រុងភ្នំពេញ

*រៀបរៀងដោយ៖ ចាន ប្រាថ្នា, សា ហ្វាទីលី, សុភ័ក្ត្រ ភាណា និង អ៊ុន សុដាវី*

*វិទ្យាស្ថានស្លឹករឹត, ខែកុម្ភៈ ឆ្នាំ២០១៥*

(តពីលេខមុន)

| លេ.រ | លេខកូដ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះ | ភេទ | អាយុ | ថ្ងៃមរណភាព | ទំព័រក្នុងសៀវភៅ |
|---|---|---|---|---|---|---|---|
| ២០៨ | ៨២៣១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១២៩ |
| ២០៩ | ៨២៣៣ | Yean Choa | យាន ជ័ (源涿) | ? | ? | ? | ១៣០ |
| ២១០ | ៨២៣៦ | Sau Ram | សូ រ៉ាំ | ? | ? | ? | ១៣០ |
| ២១១ | ៨២៣៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៣០ |
| ២១២ | ៨២៤០ | Sang Pha | សាំង ផា | ស្រី | ? | ១០/០៩/១៩៨៩ | ១៣០ |
| ២១៣ | ៨២៤៣ | Nouv Saupren | នូវ សូប្រែន | ? | ? | ? | ១៣៣ |
| ២១៤ | ៨២៤៥ | Lach Boeun | ឡាច បឿន | ប្រុស | ? | ០៤/១២/១៩៨៩ | ១៣៣ |
| ២១៥ | ៨២៤៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៣៣ |
| ២១៦ | ៨២៤៨ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ២១៧ | ៨២៤៩ | Has name yet could not be readable | មានឈ្មោះតែដាច់បាត់អស់ហើយ | ? | ? | ? | |
| ២១៨ | ៨២៥០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៣៥ |
| ២១៩ | ៨២៥៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៣៩ |
| ២២០ | ៨២៥៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៣៣ |
| ២២១ | ៨២៦១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ២២២ | ៨២៦២ | Thorn Phally | ធន ផល្លី | ? | ២១ឆ្នាំ | ? | ១៣៦ |
| ២២៣ | ៨២៦៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ?/០៣/១៩៨៩ | ១៣៦ |
| ២២៤ | ៨២៦៦ | Lork? | លោក? | ប្រុស | ? | ? | ១៣៦ |
| ២២៥ | ៨២៦៧ | Hing Neng | ហ៊ីង ណេង | ? | ? | ? | ១៣៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២២៦ | ៨២៦៩ | Chhok Sim | ឆុក ស៊ីម | ស្រី | ? | ? | ១៣៩ |
| ២២៧ | ៨២៧៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៣៩ |
| ២២៨ | ៨២៧៦ | Meak Pet | មាក ពេទ្យ | ប្រុស | ១២ឆ្នាំ | ? | ១៣៩ |
| ២២៩ | ៨២៧៨ | Leng Sokha | ឡេង សុខា | ? | ? | ០២/០៨/១៩៩៨ | ១៤២ |
| ២៣០ | ៨២៨១ | Uy Phachoeng | អ៊ុយ ផ្ជឹង | ប្រុស | ? | ? | ១៤២ |
| | | Net Kim-uk | នេត គឹមអ៊ុក | ស្រី | ? | ? | |
| ២៣១ | ៨២៨៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៤២ |
| ២៣២ | ៨២៨៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៤២ |
| ២៣៣ | ៨២៨៩ | Leng Samphiech | ឡេង សំភៀច | ? | ? | ? | ១៤២ |
| ២៣៤ | ៨២៩១ | Nen Tet | ណែន តេត | ? | ? | ? | ១៤៥ |
| ២៣៥ | ៨២៩៣ | But Chann | ប៊ុត ចាន់ | ? | ? | ០៥/០២/១៩៩១ | ១៤៥ |
| ២៣៦ | ៨២៩៧ | Men Savuth *alias* Chheak | ម៉ែន សាវុធ ហៅ ឈាក | ? | ? | ? | ១៤៥ |
| ២៣៧ | ៨២០០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៤៦ |
| ២៣៨ | ៨៣០៣ | Your Heng | យូរ ហេង | ? | ? | ០៨/០៥/១៩៨២ | ១៤៦ |
| ២៣៩ | ៨៣០៨ | Soch Choeun | សុច ចឿន | ? | ? | ? | ១៤៦ |
| ២៤០ | ៨៣១៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៤៦ |
| ២៤១ | ៨៣១៥ | Ror? | ? | ? | ? | ? | ១៤៦ |
| ២៤២ | ៨៣១៨ | Mom Channly (Female child) | កុមារី ម៉ុម ចាន់លី | ស្រី | ? | ២៣/០៩/១៩៨៧ | ១៤៩ |
| ២៤៣ | ៨៣២១ | Has name yet could not be readable | មានឈ្មោះតែមើលមិនច្បាស់ | ? | ? | ? | ១៤៩ |
| ២៤៤ | ៨៣២២ | Heng Phanna *alias* Iv Ny | ហេង ផាន់ណា ហៅ អ៊ីវ នី | ប្រុស | ? | ០៩/០៧/១៩៨៤ | ១៤៩ |
| ២៤៥ | ៨៣២៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៤៩ |
| ២៤៦ | ៨៣២៤ | Roat Bunchhan | រ័ត្ន ប៊ុនឆាន | ? | ? | ? | ១៤៩ |
| ២៤៧ | ៨៣២៥ | Khiev Pros | ខៀវ ប្រុស | ប្រុស | ? | ? | ១៥០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៤៨ | ៨៣២៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៥០ |
| ២៤៩ | ៨៣២៣ | Yung Yang Sieng | យុង យាំងសៀង | ? | ៣៥ឆ្នាំ | ២៨/០៩/១៩៨៩ | ១៥០ |
| ២៥០ | ៨៣៣១ | Chhaom Long | ឆោម ឡុង | ? | ? | ១២/០៧/១៩៩១ | ១៥០ |
| ២៥១ | ៨៣៣៦ | Huy Khann | ហ៊ុយ ខាន់ | ? | ? | ២៤/០៨/១៩៨២ | ១៥០ |
| ២៥២ | ៨៣៣៨ | Tiep Chaokivinh | ទៀប ចៅគិវិញ | ? | ? | ? | ១៥៣ |
| ២៥៣ | ៨៣៩៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៥៣ |
| ២៥៤ | ៨៣៩៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៥៣ |
| ២៥៥ | ៨៤០១ | An Seng (at Kampong Thma) | អាន សេង (នៅកំពង់ថ្ម) | ? | ? | ២៥/០១/១៩៨៧ | ១៥៣ |
| ២៥៦ | ៨៤០២ | Sek Sokha | សេក សុខា | ? | ? | ១៤/០៥/១៩៩៦ | ១៥៣ |
| ២៥៧ | ៨៤០៥ | Saur Limkenra | សូរ លឹមកេនរ៉ា | ? | ? | ? | ១៥៤ |
| ២៥៨ | ៨៤០៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៥៤ |
| ២៥៩ | ៨៤១២ | Nao Nuon | ណៅ នួន | ? | ? | ? | ១៥៤ |
| ២៦០ | ៨៤១៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៥៤ |
| ២៦១ | ៨៤២០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៥១ |
| ២៦២ | ៨៤២១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៥៤ |
| ២៦៣ | ៨៤២៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៥៩ |
| ២៦៤ | ៨៤៣៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៥៧ |
| ២៦៥ | ៨៤៣៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៥៩ |
| ២៦៦ | ៨៤៣៧ | Tang Limchheng | តាំង លឹមឆេង | ? | ? | ? | ១៥៩ |
| ២៦៧ | ៨៤៣៨ | Kim San | គឹម សាន | ? | ? | ? | ១៥៩ |
| ២៦៨ | ៨៤៤០ | Prak Savan | ប្រាក់ សាវ៉ាន | ? | ? | ២៥/០៨/១៩៨១ | ១៥៩ |
| ២៦៩ | ៨៤៤៥ | Chao Sam | ចៅ សាំ | ? | ? | ០៨/០២/១៩៨៥ | ១៦០ |
| ២៧០ | ៨៤៤៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៦០ |

(នៅមានត)

# ដំណឹងសួររកឪពុក

នាងខ្ញុំឈ្មោះ ស៊ូ បូរ៉ាមី ភេទស្រី អាយុ៥១ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិ៥ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។ នាងខ្ញុំជាកូនច្បងនៅក្នុងគ្រួសារ ដែលមានបងប្អូនបង្កើតចំនួន៣នាក់៖ ទី១) នាងខ្ញុំ,ទី២) ស៊ូ ពេជ្រ (ភេទប្រុស),ទី៣) ស៊ូ សុធារី (ភេទស្រី) និង ទី៤) ស៊ូ ស្រីល័ក្ខ (ភេទស្រី)។ នាងខ្ញុំមានម្ដាយឈ្មោះ អោម ណារី និងឪពុកឈ្មោះ ស៊ូ ណៃម។

នាងខ្ញុំសូមប្រកាសរកឪពុកឈ្មោះ ស៊ូ ណៃម។ នៅពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តកំពង់ស្ពឺ។ នៅទីនោះមិនបានប៉ុន្មានខែផង ខ្មែរក្រហមក៏បានជម្លៀសគ្រួសារនាងខ្ញុំ ទៅរស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ នៅឆ្នាំ១៩៧៦ ឪពុករបស់នាងខ្ញុំត្រូវបានខ្មែរ-ក្រហម ហៅទៅរៀនសូត្រនៅផ្សារមួយក្នុងឃុំព្រះនេត្រព្រះ បន្ទាប់មកខ្មែរក្រហមបានយកគាត់ដាក់នៅវត្តព្រះនេត្រព្រះ ជាមួយឈ្មោះ ម៉ែន ហឿន ដែលជាមិត្តភក្តិជិតស្និទ្ធរបស់គាត់ និងអ្នកដែលមានចំណេះដឹងប្រមាណ ៥០នាក់ទៀត។

ក្រោយរបបខ្មែរក្រហមបានដួលរលំ ម្ដាយនាងខ្ញុំបានជួបជាមួយអ្នកធ្លាប់ធ្វើម្ហូប និងដាំបាយនៅគុកទួលស្លែង ដែលផ្ទះរបស់គាត់នៅជាប់ជាមួយផ្ទះរបស់ខ្ញុំកាលពីសង្គមចាស់។ គាត់បានប្រាប់ម្ដាយខ្ញុំថា គាត់បានឃើញខ្មែរក្រហមដឹកឪពុករបស់ខ្ញុំ ចូលទៅគុកទទួលស្លែងយ៉ាងច្បាស់ផ្ទាល់ភ្នែក។ ទោះបីជាយ៉ាងនេះក្ដី នាងខ្ញុំបានខិតខំស្វែងរករូបថត និងចម្លើយសារភាពរបស់ឪពុកខ្ញុំ តែរកមិនឃើញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ប្រសិនបើបងប្អូនណាបានស្គាល់ ឬធ្លាប់ឮឈ្មោះ ឪពុកនាងខ្ញុំឈ្មោះ ស៊ូ ណៃម សូមមេត្តាទំនាក់ទំនងតាមរយៈអាសយដ្ឋាន៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬតាមរយៈទូរសព្ទលេខ ០២៣ ២១៤ ០ ០៩ ឬ ០១២ ៩៩៦ ៧៥០ និងសារអេឡិចត្រូនិច truthbunthorn.s@dccam.org។

**សូមអរគុណ!**



ស៊ូ បូរ៉ាមី បច្ចុប្បន្នជាគ្រូបង្រៀននៅសាលកវិទ្យាល័យភូមិន្ទភ្នំពេញ



ឪពុកម្ដាយ និងប្អូនប្រុសរបស់ បូរ៉ាមី



មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org
A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue ---, -------------- 20----- ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M BRK, 30 Ocotber 2018.